# ជំពូកទី ៦
# ការចូលរួមពីសាធារណៈជន

## ៦.១. សេចក្តីផ្តើម

១. ការពិភាក្សា និងពិគ្រោះយោបល់ជាមួយនឹងសាធារណៈជន ក្រសួង មន្ទីរ ស្ថាប័នជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន តំណាងក្រុមហ៊ុន តំណាងអង្គការពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន គឺជាចំណុចមួយដ៏សំខាន់ ដែលធ្វើឡើងដើម្បីបង្ហាញនូវផលប៉ះពាល់ ដែលកើតមានក្នុងតំណាក់កាលអនុវត្តគម្រោង សម្រាប់យកមកវិភាគឲ្យបានល្អិតល្អន់ មូលមតិគ្នាដោះស្រាយ ក្នុងគោលបំណងទទួលបានមកវិញនូវផលល្អប្រសើរចេញពីការបាត់បង់ធនធានធម្មជាតិដោយសារគម្រោងអភិវឌ្ឍន៍ ដោយការសម្បទានគ្នាទៅវិញទៅមក និងដើម្បីឲ្យអ្នកពាក់ព័ន្ធចូលរួមទាំងអស់ជួយផ្តល់នូវមតិយោបល់ និងសំណូមពរ សំដៅទប់ស្កាត់ការបង្កហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយថាហេតុតាមរយៈវិធានការកាត់បន្ថយយ៉ាងមានប្រសិទ្ធិភាព ជួយដល់ការអនុវត្តន៍គម្រោងឲ្យមានការវិវត្តន៍ទៅមុខយ៉ាងរលូនប្រកបដោយនិរន្តរភាព។

Draft

## ៦.២ ការចូលរួមរបស់សាធារណៈជន

### ៦.២.១ ការផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋានពីគម្រោងអភិវឌ្ឍន៍

២. ក្នុងតំណាក់កាលនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក សឺវីស បានធ្វើលិខិតស្នើសូមការអនុញ្ញាតពីក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះនូវបញ្ហាពាក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

- លិខិតលេខ ets/ nv-08-08/14 របស់ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ខូអិលធីឌី គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ស្តីពីសំណើសុំពិនិត្យទម្រង់ លក្ខខណ្ឌ វិសាលភាព វិធីសាស្ត្រ កាលវិភាគ និងសមាសភាពក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)។
- លិខិតលេខ 02-10-14/ETS របស់ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ខូអិលធីឌី គោរពជូនឯកឧត្តមអភិបាលខេត្តក្រចេះ ស្តីពីសំណើសុំការអនុញ្ញាតចុះពិគ្រោះយោបល់សហគមន៍ និងរៀបចំសិក្ខាសាលាសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) ដែលមានទីតាំងស្ថិតនៅក្នុងឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។
- លិខិតលេខ ៧២០ សជណ ប.ស្ថ របស់ក្រសួងបរិស្ថានជម្រាបជូន ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ខូអិលធីឌី ស្តីពីការឯកភាពលើសំណើសុំការអនុញ្ញាតចុះសិក្សា និងពិគ្រោះយោបល់ជាសាធារណៈជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

និងសង្គមពេញលេញ លើគម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) របស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក (អេស ប៊ី ខេ) ដែលមានទីតាំងស្ថិតនៅក្នុងឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។

- លិខិតលេខ 12-11-14/ETS-43 របស់ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ខូអិលធីឌី គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ស្តីពីសំណើសុំអញ្ជើញមន្ត្រីនាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក (អេស ប៊ី ខេ) ដែលមានទីតាំងស្ថិតនៅក្នុងឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។
- លិខិតលេខ 19-11-14/ETS របស់ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ខូអិលធីឌី គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ស្តីពីសំណើសុំការអនុញ្ញាតរៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីលទ្ធផលនៃការចុះសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក (អេស ប៊ី ខេ) ដែលមានទីតាំងស្ថិតនៅក្នុងឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។

លិខិតផ្សព្វផ្សាយទាំងអស់ខាងលើ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី៦-៣។

## ៦.២.២ ការផ្តល់យោបល់របស់ក្រសួង/ស្ថាប័ន/អង្គភាព អង្គការពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន

### ៦.២.២.១ សិក្ខាសាលាស្តីពីការពិគ្រោះយោបល់លើលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និង សង្គមពេញលេញ នៅលើទីតាំងភូមិសាស្ត្រដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក (អេស ប៊ី ខេ)

កាលពីថ្ងៃទី ម្ភៃប្រាំពីរ ខែវិច្ឆិកា ឆ្នាំពីរពាន់ដប់បួន វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំសាលាខេត្តខេត្តក្រចេះ មានរៀបចំធ្វើសិក្ខាសាលា ស្តីពីការពិគ្រោះយោបល់លើលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ នៅលើទីតាំងភូមិសាស្ត្រដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក (អេស ប៊ី ខេ) និងការរៀបចំផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកចំណូលគ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ។

នៅក្នុងអង្គសិក្ខាសាលានេះ មានការចូលរួមជាគណៈអធិបតីពីលោកអភិបាលរងខេត្ត នាយក-នាយករងរដ្ឋបាលសាលាខេត្ត នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត ប្រធានមន្ទីរបរិស្ថាន ប្រធានមន្ទីររ៉ែនិងថាមពល ប្រធានមន្ទីរធនធានទឹក អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អនុប្រធានមន្ទីរកសិកម្ម អនុប្រធានមន្ទីរការងារ អភិបាលស្រុកចិត្របុរី ប្រធាន និងអនុប្រធានការិយាល័យនៃក្រសួងបរិស្ថាន ប្រធានអង្គការ CED ប្រចាំខេត្តក្រចេះ តំណាងអង្គការ OXFAM អ្នកសំរបសម្រួលរបស់អង្គការអាដហុក នាយខណ្ឌរដ្ឋបាលជលផល នាយរងផ្នែករដ្ឋបាលព្រៃ

ឈើប្រចាំខេត្តក្រចេះ នាយរងសង្កាត់ព្រៃឈើឃុំកន្ទួត អនុប្រធានការិយាល័យនៃមន្ទីរកសិកម្ម អនុប្រធានការិយាល័យនៃមន្ទីរអភិវឌ្ឍន៍ជនបទ មេឃុំថ្មី មេឃុំកន្ទួត មេភូមិអាលច មេភូមិរៀរ មេភូមិថ្មី ជំនួយការមេភូមិត្នោត មន្ត្រីការិយាល័យរដ្ឋបាលសាលាខេត្ត នាយកនិងនាយករងក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស តំណាងក្រុមហ៊ុន ដូទីសាយហ្គុន-ប៊ិញហ្សឿក (អេស ប៊ី ខេ) បុគ្គលិកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស និងបុគ្គលិកក្រុមហ៊ុន ដូទី សាយហ្គុន-ប៊ិញហ្សឿក (អេស ប៊ី ខេ) សរុបចំនួន ៣៨នាក់ (ឧបសម្ព័ន្ធ៦-១ តារាង១, ឧបសម្ព័ន្ធ៦-២ រូបភាព)។ សមាសភាពចូលរួមមាន៖

**តារាង៦-១៖** សមាសភាពចូលរួមក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ នៅលើទីតាំងភូមិសាស្ត្រដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គុន-ប៊ិញហ្សឿក (អេស ប៊ី ខេ)

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន |
|---|---|---|---|---|
| ១ | លោក វ៉ា ថន | ប្រ | អភិបាលរង | ខេត្តក្រចេះ |
| ២ | ប៉ែន លីណាត | ប្រ | នាយករដ្ឋបាល | សាលាខេត្ត |
| ៣ | អ៊ឹម ពិសី | ប្រ | នាយករងរដ្ឋបាល | សាលាខេត្ត |
| ៤ | ហង់ មន្នីរ | ប្រ | នាយករង | សាលាខេត្ត |
| ៥ | អោក ដារុន | ប្រ | អនុប្រធានការិយាល័យ | មន្ទីរកសិកម្ម |
| ៦ | អ៊ូ សុភ័ក្ត | ប្រ | ប្រធានការិយាល័យEIA | ក្រសួងបរិស្ថាន |
| ៧ | ចោង គឹមជប់ | ប្រ | នាយកទីចាត់ការរដ្ឋបាល | សាលាខេត្ត |
| ៨ | សួន ញ៉ាក | ប្រ | អភិបាលស្រុក | ស្រុកចិត្របុរី |
| ៩ | សៀន គិន | ប្រ | នាយខណ្ឌ | រដ្ឋបាលជលផល |
| ១០ | គុង ពិសិដ្ឋ | ប្រ | មន្ត្រីផែនការ | មន្ទីរផែនការ |
| ១១ | ណុប ចន្ទី | ប្រ | ប្រធានមន្ទីរ | មន្ទីរបរិស្ថាន |
| ១២ | យិន បូទុម | ស្រ | អនុប្រធានមន្ទីរ | មន្ទីរដែនដីនគរូបនីយកម្ម |
| ១៣ | ម៉ៅ វិចិត្រ | ប្រ | អនុប្រធានមន្ទីរ | មន្ទីរកសិកម្ម |
| ១៤ | សាមុត លីម៉ា | ប្រ | នាយកទីចាត់ការ PID | សាលាខេត្ត |
| ១៥ | សុខ គីរីរតន៍ | ប្រ | ប្រធានមន្ទីរ | មន្ទីររ៉ែ និងថាមពល |
| ១៦ | ខាន់ ប៊ុនសេង | ប្រ | អនុប្រធានមន្ទីរ | មន្ទីរការងារ |
| ១៧ | ផេង ស៊ីពិត | ប្រ | អនុប្រធានការិយាល័យ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ១៨ | យស ការី | ប្រ | ប្រធាន | អង្គការ CED |
| ១៩ | បណ្ឌិត លី សុពណ៌-មុនី | ប្រ | នាយក | ក្រុមហ៊ុន ETS |
| ២០ | បណ្ឌិត អ៊ា ពណ្ណរាយ | ប្រ | នាយករង | ក្រុមហ៊ុន ETS |
| ២១ | សយ សុខដុម | ប្រ | បុគ្គលិក | ក្រុមហ៊ុន ETS |
| ២២ | ហ៊ុន វិសេស | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |

| | | | | |
|---|---|---|---|---|
| ២៣ | អ៊ឹម សុធី | ប្រ | តំណាងក្រុមហ៊ុន | ក្រុមហ៊ុន DTSG-BP |
| ២៤ | ឃួន សារ៉ាន់នី | ប្រ | មេភូមិ | ភូមិអាលច |
| ២៥ | ស៊ឹង ផល | ប្រ | មេឃុំ | ឃុំកន្ទួត |
| ២៦ | អ៊ាត ញ៉ុញ | ប្រ | មេភូមិ | ភូមិប្អៀរ |
| ២៧ | មុំ ខាំ | ប្រ | មេឃុំ | ឃុំថ្មី |
| ២៨. | ហេង វ័ត្ថម៉ូនីដា | ប្រ | ប្រធានមន្ទីរ | មន្ទីរធនធានទឹក និងឧតុនិយម |
| ២៩ | ផាន់ វណ្ណៈ | ប្រ | ជំនួយការភូមិ | ភូមិត្នោត |
| ៣០ | សេន អឿន | ប្រ | មេភូមិ | ភូមិថ្មី |
| ៣១ | ឈុន សំណាង | ប្រ | អនុប្រធានការិយាល័យEIA | ក្រសួងបរិស្ថាន |
| ៣២ | ហ៊ាន ដារ៉ាគុណ | ស្រ | អ្នកសម្របសម្រួល | អង្គការអាដហុក |
| ៣៣ | ចាប ចាន់ថុល | ប្រ | នាយរងផ្នែក | រដ្ឋបាលព្រៃឈើក្រចេះ |
| ៣៤ | ឈុន សុខេន | ប្រ | នាយរងសង្កាត់ | រដ្ឋបាលព្រៃឈើកន្ទួត |
| ៣៥ | អ៊ី នល់ | ប្រ | មន្ត្រីការិយាល័យ | សាលាខេត្ត |
| ៣៦ | ហង្ស សំណាង | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ៣៧ | កែវ សុវណ្ណ | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ៣៨ | មាន មានិត | ប្រ | មន្ត្រីគម្រោង | អង្គការ OXFAM |

**លោក វ៉ា ថន អភិបាលរងខេត្តក្រចេះ** បានមានប្រសាសន៍បើកអង្គសិក្ខាសាលា ដោយបានលើកបង្ហាញអំពីគោលបំណងនៃអង្គសិក្ខាសាលា ក្នុងនោះមានៈ ភាពចាំបាច់នៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ការពិភាក្សាពិគ្រោះយោបល់លើរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃនេះ ព្រមទាំងការពិគ្រោះយោបល់អំពីការរៀបចំផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍សម្រាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជម្រើសនៃការរកប្រាក់ចំណូលគ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ និងអំពីផែនការប្រើប្រាស់មូលនិធិស្តារគុណភាពបរិស្ថាន។

បន្ទាប់ពីប្រសាសន៍បើកអង្គសិក្ខាសាលារបស់លោក វ៉ា ថន អភិបាលរងខេត្តក្រចេះរួចមក **បណ្ឌិត លី សុពណ៌-មុនី** នាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស បានធ្វើបទបង្ហាញជូនអង្គសិក្ខាសាលាអំពីប្រវត្តិដីសម្បទានសេដ្ឋកិច្ចនេះ លទ្ធផលនៃការសិក្សាអង្កេតលើធនធានបរិស្ថានដែលមានស្រាប់ ក្នុងនោះមានធនធានរូបសាស្ត្រ (កត្តាអាកាសធាតុ ប្រភពទឹក ប្រភេទសិលាមេ ប្រភេទដី និងប្រភេទគុណភាពដី) ធនធានជីវសាស្ត្រ (រុក្ខអេកូឡូស៊ីៈ ប្រភេទឈើ រុក្ខជាតិ តិណជាតិ និងជល្លព្រឹក្ស, សត្វអេកូឡូស៊ីៈ ប្រភេទសត្វព្រៃថនិកសត្វ សកុណជាតិ និងមច្ឆាជាតិ) ដែលមានស្រាប់ក្នុងតំបន់គម្រោងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក ក្នុងភូមិសាស្ត្រឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ (ឧបសម្ព័ន្ធ ៦-៣ បទបង្ហាញស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ)។

Draft

បន្ទាប់ពីការធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាអង្កេតលើធនធានបរិស្ថានដែលមានស្រាប់ របស់ **បណ្ឌិត លី សុពណ៌-មុនី** រួចមក **បណ្ឌិត អ៊ា ពណ្ណរាយ** នាយករងក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស បានបន្តធ្វើបទបង្ហាញអំពីលទ្ធផលនៃការសិក្សាអង្កេតលើធនធានសង្គមនៅលើទីតាំងគោលដៅ មានដូចជាក្នុងឃុំកន្ទួត៖ ភូមិអាលច (មានភូមិស្រែននក្នុង ជាភូមិឧបសម្ព័ន្ធ) និងក្នុងឃុំថ្មី៖ ភូមិថ្មី ភូមិរបៀរ ភូមិស្វាយជ្រុំ ភូមិ ក្រសាំង ភូមិត្នោត (មានភូមិយ៉ៃ ជាភូមិឧបសម្ព័ន្ធ) នៃស្រុកចិត្របុរី ខេត្តក្រចេះ។ បទបង្ហាញនេះបានផ្តោតទៅលើរបាយប្រជាសាស្ត្រ (ស្ថិតិប្រជាពលរដ្ឋ របាយជនជាតិ ទំហំគ្រួសារមធ្យម ប្រភេទផ្ទះ) ចំនួនសមាជិកគ្រួសារទៅតាមចន្លោះអាយុ មធ្យមភាគចំនួនសមាជិកនិងមេគ្រួសារតាមភេទ ប្រភពចំណូលទី១ ទី២ និងទី៣ មធ្យមភាគនៃប្រាក់ចំណូលប្រចាំខែរបស់ប្រជាពលរដ្ឋ ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃ ធៀបនឹងកម្រិតបន្ទាត់នៃភាពក្រីក្រដែលកំណត់តាមការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាឆ្នាំ ២០០៩ (ជាពិសេស ការរកឃើញថា អ្នកភូមិស្វាយជ្រុំមានប្រាក់ចំណូលមធ្យមប្រចាំថ្ងៃទាបជាង ឬស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ) មធ្យមភាគនៃទំហំដីកសិកម្មរបស់គ្រួសារប្រជាពលរដ្ឋ ការទទួលបាននូវសេវាសាធារណៈ (ផ្លូវគមនាគមន៍ អគ្គិសនី ទឹកស្អាត បង្គន់អនាម័យស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ) ការសិក្សាអប់រំ (កម្រិតអប់រំរបស់សមាជិកនិងមេគ្រួសារ ការសម្រេចចិត្តឈប់និងបន្តការសិក្សា មូលហេតុនៃការឈប់សិក្សា) សុខាភិបាល (ស្ថានភាពសុខភាព និងជម្ងឺដែលជួបប្រទះក្នុងតំបន់ពាក់ព័ន្ធ ការទទួលបានសេវាសុខភាព ចម្ងាយនិងមធ្យោបាយធ្វើដំណើរទៅកាន់មណ្ឌលសុខភាព និងគ្លីនិកឯកជន) ការអាស្រ័យធនធានធម្មជាតិនិងកម្រិតនៃផលប៉ះពាល់សេដ្ឋកិច្ចគ្រួសារជាដើម។ ក្រៅពីនោះក៏មានលទ្ធផលនៃការសិក្សាអង្កេតលើប្រពៃណី ទំនៀមទំលាប់ ជំនឿ ព្រៃកប់ខ្មោច សំណង់ប្រវត្តិសាស្ត្រ និងសម្បត្តិវប្បធម៌របស់ប្រជាពលរដ្ឋ (រួមទាំងជនជាតិដើមភាគតិច) ក្នុងតំបន់ផងដែរ (ឧបសម្ព័ន្ធ៦-៣ បទបង្ហាញស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ)។

បន្ទាប់ពី **បណ្ឌិត អ៊ា ពណ្ណរាយ** ធ្វើបទបង្ហាញអំពីលទ្ធផលនៃការសិក្សាអង្កេតលើធនធានសង្គមនៅលើទីតាំងគោលដៅរួចមក **បណ្ឌិត លី សុពណ៌-មុនី** បានបង្ហាញពីកំរិតផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសង្គម (ផលប៉ះពាល់អវិជ្ជមាន និងវិជ្ជមាន លើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសង្គម) របស់គម្រោងវិនិយោគ ព្រមទាំងវិធានការកាត់បន្ថយនានានៅតំណាក់កាលមុនប្រតិបត្តិការដាំដុះ ក្នុងតំណាក់កាលប្រតិបត្តិការដាំដុះ និងក្នុងតំណាក់កាលក្រោយប្រតិបត្តិការដាំដុះ។ បន្ទាប់មក **បណ្ឌិត លី សុពណ៌-មុនី** ក៏បានលើកឡើងអំពីលទ្ធផលនៃការសិក្សាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋថ្នាក់មូលដ្ឋាននៅក្នុងឃុំទាំងពីរ (ឃុំថ្មី និងឃុំកន្ទួត) កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៤ កន្លងទៅនេះ។ នៅក្នុងការសិក្សាអង្កេត និងពិគ្រោះយោបល់ថ្នាក់មូលដ្ឋាននេះ បានបង្ហាញពីលទ្ធផលនៃការដោះស្រាយបញ្ហាពាក់ព័ន្ធទាំងឡាយរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុនដូទីសាយហ្គន-ប៊ិញហឿក ពីការធ្វើសម្បទានគ្នាទៅវិញទៅមក និងការឈានទៅដល់ការយល់ព្រមគ្នា ទាំងខាងប្រជាពលរដ្ឋ និងទាំងខាងក្រុមហ៊ុន ហើយមានការសន្យារបស់ក្រុមហ៊ុនតាមសំណូមពររបស់ប្រជាពលរដ្ឋទៀតផង។ នៅសល់តែបញ្ហាទាមទារសុំដីបន្ថែមចំនួន ៥៤៥,២៤ហិកតារបស់ប្រជាពលរដ្ឋប៉ុណ្ណោះ ដែលត្រូវរង់ចាំការដោះស្រាយតាមចំណាត់ការរបស់អាជ្ញាធរខេត្តក្រចេះ។ រាល់សំណូមពរទាំងឡាយរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង នឹងបានក្លាយជាប្រធានបទសម្រាប់ការពិភាក្សាពិគ្រោះយោបល់នៅក្នុងអង្គសិក្ខាសាលានេះ ហើយតាមរយៈអនុសាសន៍នៃអង្គសិក្ខា

Draft

សាលានេះ ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស នឹងមានលទ្ធភាពរៀបចំធ្វើផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ សម្រាប់ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ តាមរយៈការផ្តល់នូវជម្រើសនៃការរកប្រាក់ចំណូលគ្រួសារ ដើម្បីបង្កើនកំរិតជីវភាពរបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធក្នុងតំបន់គម្រោង។ ក្នុងជម្រើសនៃការរកប្រាក់ចំណូលគ្រួសារនេះ ក្រុមការងារ អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស បានលើកជាមតិក្នុងបំណងផ្លាស់ប្តូរការធ្វើស្រែតាមរដូវទៅជាការដាំស្វាយចន្ទីដែលជាដំណាំកសិកម្មផ្តល់ផលរយៈពេលវែង និងការវិភាគសេដ្ឋកិច្ចដោយធ្វើការប្រៀបធៀបពីការចំណាយនិងចំណូលលើដំណាំស្រូវ ជាមួយនឹងការចំណាយនិងចំណូលលើការដាំស្វាយចន្ទី សម្រាប់ឲ្យប្រជាពលរដ្ឋធ្វើការជ្រើសរើស។ យោងតាមការសិក្សាអង្កេតអំពីកំរិតជីវភាពរបស់ប្រជាពលរដ្ឋ និងទីតាំងភូមិសាស្ត្រនៃភូមិនីមួយៗក្នុងតំបន់គោលដៅដែលងាយទទួលរងគ្រោះពីធម្មជាតិនោះ ក្រុមការងារបានកំនត់យកភូមិឧបសម្ព័ន្ធស្រែនន និងយ៉ៃ ដើម្បីអនុវត្តផែនការគំរូនេះ។ ប៉ុន្តែ ក្រោយពីទទួលបានទិន្នន័យនៃការវិភាគលើកំរិតជីវភាពរបស់ប្រជាពលរដ្ឋពាក់ព័ន្ធ ដោយធ្វើការប្រៀបធៀបប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃរបស់ពួកគាត់ទៅនឹងកម្រិតបន្ទាត់នៃភាពក្រីក្រ ដែលកំណត់តាមការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាឆ្នាំ ២០០៩ ក្រុមការងារបានរកឃើញថា នាពេលបច្ចុប្បន្នកំរិតជីវភាពរបស់អ្នកភូមិស្វាយជ្រុំកំពុងស្ថិតនៅក្រោមបន្ទាត់ក្រីក្រ ដូច្នេះត្រូវជ្រើសរើសភូមិនេះសម្រាប់អនុវត្តផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍គំរូនេះជាមួយនឹងភូមិពីរខាងលើផងដែរ។ ដើម្បីជាប្រធានបទសម្រាប់អង្គសិក្ខាសាលាធ្វើការពិភាក្សានោះ ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស បានលើកជាសំណើថា: សូមជ្រើសរើសយកភូមិស្វាយជ្រុំ ភូមិឧបសម្ព័ន្ធស្រែននក្នុង និងភូមិឧបសម្ព័ន្ធយ៉ៃ ធ្វើជាភូមិគោលដៅសម្រាប់អនុវត្តផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ ដោយត្រូវជ្រើសរើសគ្រួសារប្រជាកសិករក្រីក្របំផុតពិតប្រាកដដែលមានចំការទំហំ ១១ហិកតា សរុបចំនួន ០៩គ្រួសារមកធ្វើជាគ្រួសារគម្រូសម្រាប់អនុវត្តផែនការដាំស្វាយចន្ទីបង្ហាញនេះ ក្នុងនោះ០៥គ្រួសារនៅភូមិស្វាយជ្រុំ ០២គ្រួសារនៅភូមិឧបសម្ព័ន្ធស្រែននក្នុង និង០២គ្រួសារនៅភូមិឧបសម្ព័ន្ធយ៉ៃ ហើយគ្រួសារនីមួយៗត្រូវមានភារកិច្ចព័ទ្ធរបងចម្ការ សម្អាតដី ព្រមទាំងត្រៀមកម្លាំងសម្រាប់ការងារដាំដុះ និងថែទាំនូវដំណាំស្វាយចន្ទីរបស់ខ្លួន។ ក្រុមហ៊ុនដូទីសាយហ្គុន-បិញហ្វៀក មានភារៈកិច្ចទទួលនូវការងារបច្ចេកទេសដាំដុះ ដាក់ជីបំប៉ន និងការផ្តល់ពូជ ដោយប្រើប្រាស់នូវមូលនិធិអភិវឌ្ឍន៍សហគមន៍របស់ខ្លួនចំនួន ២០.០០០ដុល្លាអាមេរិកក្នុង១ឆ្នាំ។ ចំណែកការត្រួតពិនិត្យតាមដាន និងវាយតម្លៃជាភារៈកិច្ចរបស់ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស។ ក្រុមហ៊ុនដូទីសាយហ្គុន-បិញហ្វៀកនិងជួយឧបត្ថម្ភជាបច្ចេកទេសនិងពូជ ក្នុងរយៈពេល ០៣ឆ្នាំ គឺរហូតដល់ដើមស្វាយចន្ទីឲ្យផល។ ដូចនេះសូមអង្គសិក្ខាសាលាទាំងមូល ជួយផ្តល់ជាមតិយោបល់ឲ្យបានផុលផុសទាំងអស់គ្នា ដើម្បីអនុម័តនូវផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍នេះឲ្យបានឆាប់រហ័សកាន់តែប្រសើរ។ លើសពីនេះទៅទៀត ក្រុមហ៊ុនក៏នៅមានមូលនិធិដែលមានទឹកប្រាក់ ២៥.០០០ដុល្លាអាមេរិក/ឆ្នាំ សម្រាប់កម្មវិធីស្តារគុណភាពបរិស្ថានផងដែរ។

បន្ទាប់មក **លោក ម៉ៅ វិចិត្រ អនុប្រធានមន្ទីរកសិកម្ម** បានមានសំណួរថា: តើផ្ទៃដីដែលទទួលបានសិទ្ធប្រទានពីរាជរដ្ឋាភិបាលកម្ពុជា មានប៉ុន្មានហិកតាពិតប្រាកដ ៦.៤៣៦ហិកតា ឬក៏ ៥.៤៣៦ហិកតា? ព្រោះបើនៅក្នុងឯកសារសិទ្ធិប្រទានមានដាក់ថា ៦.៤៣៦ហិកតា ប៉ុន្តែនៅក្នុងបទបង្ហាញនេះ បែរជាមានតែ ៥.៤៣៦ហិកតាទៅវិញ។

Draft

**បណ្ឌិត លី សុពណ៌-មុនី** បានឆ្លើយថា: តួលេខទាំងអស់ដែលយកមករៀបចំជាបទបង្ហាញនេះ គឺក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក សឺវែ បានយកចេញពីផែនការមេរបស់ក្រុមហ៊ុន ដែលធ្វើដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយតួលេខក្នុងនោះគឺ ៥.៤៣៦ហិកតា ប៉ុន្តែក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក សឺវែ នឹងធ្វើការពិនិត្យឯកសារច្បាប់ (លិខិតសិទ្ធប្រទានពីរាជរដ្ឋាភិបាល)ម្តងទៀត។ បើយោងតាមផែនការមេរបស់ក្រុមហ៊ុន មានចំណុចមួយបានចែងថា ក្រុមហ៊ុនបានស្នើសុំដីសម្បទានដំបូងចំនួន ១០.០០០ហិកតាសំរាប់វិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម។ បន្ទាប់ពីក្រុមការងាររបស់លេខាធិការដ្ឋានបច្ចេកទេសសំរាប់សម្បទានដីសេដ្ឋកិច្ច និងក្រុមការងារចុះកំណត់ព្រំគោលដីសម្បទាន ធ្វើការសិក្សាវាយតម្លៃនិងពិនិត្យរួច ឃើញថា លើទីតាំងស្នើសុំនេះមានផ្ទៃដីសរុបចំនួន ៩.៧៣៨ហិកតា ហើយត្រូវកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធចំនួន ៤.៣០២ហិកតា ក្នុងនោះមាន:

- ដីប្រជាពលរដ្ឋចំនួន: ២.៥៣១ហិកតា (ដីពាក់ពន្ធ័ប្រជាពលរដ្ឋដែលត្រូវកាត់ចេញលើកចុងក្រោយដោយក្រុមការងារក្រសួងមាន ១.៦៩០ហិកតា និងដីដែលរដ្ឋបាលព្រៃឈើស្នើឱ្យកាត់មាន៨៤១ហិកតា តាមលិខិតចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ(២០០៧។
- ដីព្រៃល្បោះបៃតង ចំនួន: ១.០២៣ហិកតា
- ដីព្រៃល្បោះតាមមាត់អូរចំនួន: ៥៩៥ហិកតា
- ដីពុំមានគម្របព្រៃ បឹង ស្ទឹង វាលស្មៅចំនួន: ១៥៣ហិកតា

ដូច្នេះផ្ទៃដីនៅសល់សំរាប់ក្រុមហ៊ុនអាចធ្វើអាជីវកម្ម-ផលិតកម្មមានចំនួនសរុប ៥.៤៣៦ហិកតា (៩.៧៣៨ហិកតា – ៤.៣០២ហិកតា = ៥.៤៣៦ហិកតា)។

លើសពីនេះទៅទៀត នៅក្នុងផែនការមេដដែល ត្រង់កថាខ័ណ្ឌនិងតារាងផែនការបែងចែកផ្ទៃដីដាំដុះ និងហេដ្ឋារចនាសម្ព័ន្ធពីឆ្នាំទី១ដល់ឆ្នាំទី៤ មានបង្ហាញដូចខាងក្រោមថា៖

**តារាង ៦-២៖ ផែនការបែងចែកផ្ទៃដីដាំដុះ និងហេដ្ឋារចនាសម្ព័ន្ធ ពីឆ្នាំទី១ ដល់ឆ្នាំទី៤ ៖**

| លរ. | មុខដំណាំ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | សរុប |
|---|---|---|---|---|---|---|
| ១ | ផ្ទៃដីដាំកៅស៊ូ | ៩០០ | ១.៥០០ | ១.៥០០ | ៦០០ | ៤.៥០០ |
| ២ | ស្វាយចន្ទី | | ២០០ | ២០០ | ១០០ | ៥០០ |
| សរុបផ្ទៃដីដាំដុះដំណាំ | | ៩០០ | ១.៧០០ | ១.៧០០ | ៧០០ | ៥.០០០ |
| ៣ | ហេដ្ឋារចនាសម្ព័ន្ធនានា | ១០០ | ១០០ | ១០០ | ១៣៦ | ៤៣៦ |
| សរុបផ្ទៃដីអាជីវកម្ម | | ១.០០០ | ១.៨០០ | ១.៨០០ | ៨៣៦ | ៥.៤៣៦ |
| ៤ | ផ្ទៃដីទ្រនាប់ដងអូរ | ៥៤១ | ៩៩៤ | ១.៣៦៤ | ៤០៣ | ៣.៣០២ |
| ផ្ទៃដីពាក់ព័ន្ធប្រជាពលរដ្ឋ រកឃើញបន្ថែមពេលចុះកំណត់ព្រំដោយក្រុមការងារនិងស្ថិតនៅរាយប៉ាយក្នុងដីសម្បទាន | | | | | | ១.០០០ |
| សរុបរួម (ហិកតា) | | ១.៥៤១ | ២.៧៩៤ | ៣.១៦៤ | ១.២៣៩ | ៩.៧៣៨ |

យោងតាមទិន្នន័យទាំងអស់ខាងលើនេះ ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក សឺវីស អាចធ្វើការសន្និដ្ឋានបានថា ថ្វីត្បិតនៅក្នុងសិទ្ធិប្រទានលេខ៣២ សប្រទ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលស្តីពីការប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទានចំនួន ៦.៤៣៦ហិកតា សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ជាមួយក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក** (អេស ប៊ី ខេ) និងក្នុងកិច្ចសន្យាចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក** (អេស ប៊ី ខេ) នៅលើផ្ទៃដីសរុបចំនួន ៦.៤៣៦ហិកតាក៏ពិតមែន ប៉ុន្តែនៅពេលដែលក្រុមការងារចុះវាស់វែងកំណត់ព្រំដី បានប្រទះឃើញនូវផ្ទៃដីពាក់ព័ន្ធប្រជាពលរដ្ឋ ដែលស្ថិតនៅរាយប៉ាយក្នុងដីសម្បទានចំនួន ១.០០០ហិកតាបន្ថែមទៀតដែលត្រូវបានកាត់ចេញដោយក្រុមការងារផងដែរ ដូច្នេះផ្ទៃដីនៅសល់សម្រាប់ធ្វើអាជីវកម្ម-ផលិតកម្មគឺ ៥.៤៣៦ហិកតា (៦.៤៣៦ហិកតា - ១.០០០ហិកតា = ៥.៤៣៦ហិកតា) ប៉ុណ្ណោះ។

**លោក ហេង រ័ត្នម៉ូនីដា ប្រធានមន្ទីរធនធានទឹក និងឧតុនិយម** បានលើកសំណួរថាៈ តើក្រុមហ៊ុនមានបានរក្សាទុកដីចំណីព្រែកទេរ (ដីទ្រនាប់ដងព្រែកទេរ) ដែរឬទេ? បើមាន តើចម្ងាយប៉ុន្មានពីមាត់ព្រែក? ហើយលោកក៏បានស្នើឲ្យសាងសង់អណ្តូងទឹកនៅស្រែនន ស្វាយជ្រុំ ឡៀរ និងនៅទីតាំងពាក់ព័ន្ធផ្សេងទៀត ដើម្បីសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង។ ហើយបើអាចមានលទ្ធភាព គួរសាងសង់ជាអណ្តូងទឹកដែលមានភ្ជាប់ប្រព័ន្ធទាញយកថាមពលពន្លឺព្រះអាទិត្យមកបូមទឹកប្រើប្រាស់តែម្តង ក៏ជាការងារមួយល្អដែរ។ អណ្តូងប្រភេទនេះ មានតម្លៃប្រមាណជា ១០.០០០ដុល្លារអាមេរិក ប៉ុណ្ណោះ។

**លោក អ៊ឹម** សុធី តំណាងឲ្យក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហឿក បានមានប្រសាសន៍ឆ្លើយតបថាៈ តាមគោលការណ៍ច្បាប់ ក្រុមហ៊ុនត្រូវរក្សាទុកដីទ្រនាប់ប្រព័ន្ធផ្លូវទឹកចម្ងាយពីចំណុចកណ្តាលប្រមាណជា ២០០ម៉ែត្រ (គោលការណ៍ចាស់) និង ១០០-១៥០ម៉ែត្រ (គោលការណ៍ថ្មី)។ ប៉ុន្តែបើពិនិត្យតាមលក្ខណៈជាក់ស្តែង គឺក្រុមហ៊ុនបានទុកនូវដីទ្រនាប់ដងអូរនេះច្រើនជាងគោលការណ៍ទាំងពីរនឹងទៅទៀត ព្រោះប្រជាពលរដ្ឋបានតាំងទីលំនៅនៅតាមបណ្តោយព្រែកទេរ ដោយមានទាំងភូមិករ និងដីស្រែរបស់ពួកគាត់នៅខាងក្រោយភូមិទៀតផង ហេតុដូចនេះ ក្រុមហ៊ុនបានធ្វើការកាត់ឆ្វៀលដីភូមិករ និងដីស្រែខាងក្រោយភូមិរបស់ពួកគាត់ចេញទាំងអស់តាមស្ថានភាពជាក់ស្តែងរួចអស់ហើយ។

បន្ទាប់មកសមាសភាពចូលរួមអង្គសិក្ខាសាលាទាំងអស់ បានចូលរួមនូវមតិយោបល់ជុំវិញបញ្ហាការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ដែលមានទឹកប្រាក់ចំនួន ២០.០០០ដុល្លារអាមេរិក/ឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ តាមរយៈការផ្តល់នូវជម្រើសនៃការរកប្រាក់ចំណូលគ្រួសារ ដើម្បីបង្កើនកំរិតជីវភាពរបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធក្នុងតំបន់គម្រោង ដូចខាងក្រោមៈ

**លោក យស ភារី ប្រធានអង្គការ CED ប្រចាំខេត្តក្រចេះ** បានមានមតិថាៈ សំណាកគំរូ ៩គ្រួសារក្នុងតំបន់គំរោង ដែលក្រុមហ៊ុនប្រឹក្សាបានលើកឡើងហាក់ដូចជាតិចពេក ហើយមិនសមស្របទៅនឹងចំនួនគ្រួសារប្រជាពលរដ្ឋពាក់ព័ន្ធដែលសមនឹងទទួលផលនេះជាង ១៣ន់គ្រួសារនុះទេ។

**លោក មាន មានិត មន្ត្រីគម្រោងរបស់អង្គការ OXFAM** បានមានមតិថាៈ តាមរយៈការចុះធ្វើការជាមួយប្រជាពលរដ្ឋក្នុងតំបន់ បានឲ្យដឹងថាៈ ប្រជាពលរដ្ឋក្នុងតំបន់នេះមានប្រភពចំណូលទី១ មិនមែនពីការធ្វើស្រែចម្ការទេ គឺប្រភពចំណូលទី ១ បានមកពីការទទួលផលអនុផលព្រៃឈើ ដែលជាទំលាប់ចាស់របស់ពួកគាត់ សូមស្នើឲ្យក្រុមហ៊ុនប្រឹក្សាធ្វើការសិក្សាឡើងវិញម្តងទៀត។

**បណ្ឌិត លី សុពណ៌-មុនី** បានមានមតិឆ្លើយតបថាៈ ប្រហែលជាមានការស្តាប់ទៅហើយយល់ច្រឡំព្រោះនាយករងរបស់ខ្ញុំបានធ្វើការបកស្រាយយ៉ាងច្បាស់ថា ប្រភពចំណូលទី១នេះ មិនមែនជាប្រភពចំណូលចម្បងដែលអាចឲ្យប្រជាពលរដ្ឋទទួលបានប្រាក់ចំណូលច្រើនជាងគេនុះទេ គឺប្រភពចំណូលទី២ និងទី៣ឯណោះវិញទេ ដែលផ្តល់នូវប្រាក់ចំណូលច្រើនជាងប្រភពចំណូលទី១ទៅទៀត។

**លោក មុំ ខាំ មេឃុំថ្មី** បានមានមតិឆ្លើយថាៈ តាងនាមឲ្យប្រជាពលរដ្ឋក្នុងតំបន់ពាក់ព័ន្ធទាំងមូល ខ្ញុំសូមអះអាងថា ប្រភពចំណូលទី ១ របស់ប្រជាពលរដ្ឋនៅទីនោះ គឺបានមកពីស្រែចម្ការ ដោយឡែកក្រោយពីរដូវធ្វើស្រែចម្ការរួចហើយ ទើបពួកគាត់ទៅរកប្រកបការងារផ្សេងៗទៀតជាកម្រៃប្រចាំថ្ងៃ សម្រាប់បំពេញសេចក្តីត្រូវការប្រចាំថ្ងៃថែមទៀត។ សព្វថ្ងៃធនធានធម្មជាតិកំពុងតែរេចរឹលទៅៗហើយ ការស្វែងរកធនធានធម្មជាតិកាន់តែខ្សត់ទៅៗ ឆ្ងាយទៅៗ ចំណែកប្រជាពលរដ្ឋកំពុងងាកមករកការងារកសិកម្មវិញ។ ខ្ញុំសូមគាំទ្រដល់ផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍នេះទាំងស្រុង។

**បណ្ឌិត លី សុពណ៌-មុនី** បានមានមតិឆ្លើយតបបន្ថែមថាៈ ៩គ្រួសារដែលជ្រើសរើសនេះ គឺចំណុចចាប់ផ្តើមមួយ ដើម្បីបង្ហាញអំពីលទ្ធផល និងផលប្រយោជន៍នៃផែនការអភិវឌ្ឍន៍សហគមន៍ ក្នុងបំណងឲ្យប្រជាពលរដ្ឋស្វែងយល់ដោយខ្លួនដោយឯង និងស្ម័គ្រចិត្តចូលរួមកាន់តែផុលផុសឡើង។ ម៉្យាងទៀត មូលនិធិ ២០.០០០ដុល្លាក្នុងមួយឆ្នាំនេះ នឹងអនុវត្តជារៀងរាល់ឆ្នាំ ហើយមានរយៈពេលស្មើនឹងអាយុកាលនៃគម្រោងវិនិយោគនេះដែរ ដូចនេះយើងសល់ថវិកាដែលត្រូវធ្វើបន្តច្រើន ទៅតាមអាទិភាពនៃតម្រូវការ។

**លោក អ៊ី សុភ័ណ្ឌ ប្រធានការិយាល័យអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃក្រសួងបរិស្ថាន** បានមានមតិសួរទៅតំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញភឿកថាៈ

- តើក្រុមហ៊ុនបានឈូសឆាយដោយរក្សាទុកចម្ងាយពីមាត់អូរប៉ុន្មានម៉ែត្រ?
- តម្រូវការកម្លាំងពលកម្មក្នុងមួយឆ្នាំប៉ុន្មាន?

ដោយឡែកការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ ត្រូវតែធ្វើការពិភាក្សាផ្តល់យោបល់ឲ្យបានផុលផុសបន្ថែមទៀត។

**លោក ចាប ចាន់ថុល នាយករងផ្ទបាលព្រៃឈើ** បានមានមតិថាៈ ព្រៃសហគមន៍ ៤៧០ហិកតារបស់ភូមិភ្លៀរ ត្រូវថែរក្សាទុកសម្រាប់សហគមន៍។ ដោយឡែកមូលនិធិអភិវឌ្ឍន៍សហគមន៍នេះគួរប្រើប្រាស់ទៅលើការអប់រំផង ដើម្បីបង្កើនការយល់ដឹងរបស់ពួកគាត់។

**លោក ហេង រ័ត្នម៉ូនីដា ប្រធានមន្ទីរធនធានទឹក** មានប្រសាសន៍ថាៈ គួរសាងសង់ផ្លូវថ្នល់ និងមណ្ឌលសុខភាពជាមុន ដើម្បីសម្រួលដល់ការរស់នៅរបស់ពួកគាត់។

**លោក សៀន តិន នាយខណ្ឌរដ្ឋបាលជលផល** មានមតិថាៈ គួរធ្វើការអភិរក្សអន្លង់តាមព្រែក និងតាមប្រព័ន្ធផ្លូវទឹកនានាក្នុងតំបន់គម្រោង ព្រមទាំងអភិវឌ្ឍន៍ពូជត្រីក្នុងតំបន់ផងដែរ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនត្រូវតែប្រុងប្រយ័ត្នលើការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមី សំដៅការពារការបំពុលទឹក ដែលធ្វើឲ្យប៉ះពាល់ដល់មច្ឆាជាតិ។

**លោក ម៉ៅ វិចិត្រ អនុប្រធានមន្ទីរកសិកម្ម** មានមតិថាៈ គួរចុះសិក្សាស្វែងយល់អំពីតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋដែលនៅទីនោះ ដែលពួកគាត់អាចទទួលផលប្រយោជន៍ក្នុងអត្រាខ្ពស់ (ច្រើន)។

**លោក មុំ ខាំ មេឃុំថ្មី** មានមតិថាៈ ពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍នេះ ផ្លូវលំ និងទឹកស្អាត ជាបញ្ហាសំខាន់ក្នុងការអភិវឌ្ឍន៍ជនបទ ប៉ុន្តែវាត្រូវការថវិកាច្រើនណាស់ក្នុងការសាងសង់ ដូចនេះមូលនិធិ ២០.០០០ដុល្លាក្នុងមួយឆ្នាំតើអាចប្រើប្រាស់សម្រាប់ការសាងសង់ក្នុងកំរិតណា? គួរពិចារណាស្វែងយល់រកចំណុចចាប់ផ្តើមណាមួយដែលមានភាពចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍន៍ ដែលអាចប្រើប្រាស់មូលនិធិនេះបាន។ នៅក្នុងតំបន់ដាច់ស្រយាល ប្រជាពលរដ្ឋរស់នៅដោយពឹងផ្អែកលើការធ្វើស្រែចម្ការ និងការចិញ្ចឹមសត្វ ដូច្នេះបញ្ហាទាំងនេះគួរតែជាចំណុចចាប់ផ្តើមដែលត្រូវរៀបចំផែនការអភិវឌ្ឍន៍។

**លោក អ៊ឹម សុធី តំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក** បានឆ្លើយតប និងផ្តល់ជាមតិដល់អង្គសិក្ខាសាលាលើបញ្ហាការទទួលបានសេវាគមនាគមន៍សម្រាប់ជាមូលដ្ឋានសម្រាប់ការវិភាគបន្តថាៈ អង្គសិក្ខាសាលាទាំងមូលបានជ្រាបទាំងអស់គ្នាហើយថា ដីរបស់ក្រុមហ៊ុនមាន ៥.៤៣៦ហិកតា។ ឆ្លើយតបទៅនឹងសំណួរដែលសួរថា តើក្រុមហ៊ុនមានបានកាត់ដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋហើយឬនៅ? យោងតាមផែនការបែងចែកដីគឺមានអនុតំបន់ទី១ ទី២ ទី៣ និងទី៤។ អនុតំបន់ទី ១ និងទី ២ បានឈូសឆាយ និងដាំដុះរួចទាំងស្រុងហើយ នៅសល់តែអនុតំបន់ទី៣ និងទី៤ប៉ុណ្ណោះ។ ទន្ទឹមនឹងនេះដែរគឺយើងបានអនុវត្តនូវបទបញ្ជាលេខ ០១ របស់រដ្ឋាភិបាល ដែលមានក្រុមនិស្សិតស្ម័គ្រចិត្តចុះមកវាស់វែងដោះស្រាយដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋរួចទាំងស្រុង។ ក្នុងនោះក្នុងអនុតំបន់ទី១ ក្រុមនិស្សិតបានចុះវាស់វែងកាត់នូវផ្ទៃដីចំនួន ១៨៥,៤១ហិកតា ក្នុងអនុតំបន់ទី២ បានកាត់ដីអស់ចំនួន ២៦៣.៩២ហិកតា ក្នុងអនុតំបន់ទី៣ បានកាត់ចេញនូវផ្ទៃដី ១១៨,៣៦ហិកតា និងក្នុងអនុតំបន់ទី៤ បានកាត់ចេញនូវផ្ទៃដី ១៣១,៤២ហិកតា ហើយដីទាំងអស់នេះត្រូវបានរៀបចំធ្វើប្លង់និងប្រគល់ប័ណ្ណកម្មសិទ្ធកាន់កាប់រួចអស់ហើយ។ លើសពីនេះទៅទៀត ទោះបីជាមានការវាស់វែងនិងកាត់ដីពាក់ព័ន្ធជូនប្រជាពលរដ្ឋយើងហើយក៏ដោយ ក៏ក្រុមហ៊ុនបាន និងកំពុងដោះស្រាយជូនប្រជាពលរដ្ឋនូវផ្ទៃដីពាក់ព័ន្ធមួយចំនួនតូច ដែលពួកគាត់បានកាន់កាប់ជាក់ស្តែង ដោយអនុវត្តតាមរូបមន្តស្បែកខ្លាបន្តទៀត។ បច្ចុប្បន្ននៅក្នុងអនុតំបន់ទី៣ និងទី៤ ពុំមានបញ្ហាពាក់ព័ន្ធទៀតទេ ព្រោះត្រូវបានដោះស្រាយអស់ហើយ គឺពុំមានផលប៉ះពាល់អ្វីឡើយ។ តែបើយើងដេញសួរទៀតថា តើនៅមានសេសសល់ផលប៉ះពាល់អ្វីទៀតដែរឬទេ? ខ្ញុំសូមឆ្លើយថាមាន គឺមាននៅភូមិឃ្មៀរ។ បច្ចុប្បន្ន អ្នកភូមិឃ្មៀរនៅតែធ្វើការទាមទារដីមួយចំនួនបន្ថែមទៀត ហើយយើងក៏ព្យាយាមដោះស្រាយជាមួយនឹងអាជ្ញាធរដែនដីពាក់ព័ន្ធ និងអ្នកភូមិឃ្មៀរនេះចំនួន ៩ដងរួចមកហើយ ជាលទ្ធផល យើងមានការឯកភាពគ្នាជាមួយប្រជាពលរដ្ឋ



Draft

មួយចំនួន ឯមួយចំនួនទៀតនៅមិនទាន់ពេញចិត្តនឹងដំណោះស្រាយនៅឡើយ។ សរុបសេចក្ដីមក គឺក្រុមហ៊ុនបានធ្វើសម្បទានយ៉ាងច្រើន ហើយចុងក្រោយនេះតាមការសម្របសម្រួលរបស់អាជ្ញាធរខេត្ត គឺតម្រូវឲ្យក្រុមហ៊ុនកាត់ជូនពួកគាត់នូវផ្ទៃដីចំនួន ៥៤៥,២៤ហិកតាទៀត នេះមិនទាន់រាប់បញ្ចូលនូវដីដែលពួកគាត់កាន់កាប់ជាក់ស្ដែងដូចខ្ញុំបានជំរាបជូនពីខាងដើមផង។ ដូច្នេះខ្ញុំគិតថា ក្រុមហ៊ុនបានដោះស្រាយនូវបញ្ហាដីធ្លីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋបានចប់សព្វគ្រប់ទាំងស្រុងហើយ។ បន្ទាប់ពីក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក បានដោះស្រាយកាត់ដីជាង ៥៤៥,២៤ហិកតា ឲ្យប្រជាពលរដ្ឋភូមិភ្លៀរចំនួន ២២៩គ្រួសារ នៅមានក្រុមហ៊ុនភូរៀងដែលបានកាត់ដីឲ្យទៅអ្នកភូមិភ្លៀរចំនួន ១.០១៥ហិកតា សម្រាប់ប្រើប្រាស់ និងក្រុមហ៊ុនម៉ូហ៊ីបាក់បានកាត់ដីឲ្យទៅភូមិភ្លៀរចំនួនប្រហែលជា ៥២០ហិកតាផងដែរ។ ក្រៅពីនេះ អ្នកភូមិភ្លៀរនេះមានដីព្រៃសហគមន៍ចំនួន៤៧០ហិកតាទៀត បើយើងធ្វើការបូកសរុបទៅឃើញថា អ្នកភូមិភ្លៀរមានដីព្រៃជាង២.៥៥០ហិកតាសម្រាប់ប្រើប្រាស់ សួរថាចំនួនដីទាំងអស់នេះវាសមស្របទៅតាមតម្រូវការជាក់ស្ដែងរបស់អ្នកភូមិភ្លៀរដែរឬទេ?

ចំពោះការអភិវឌ្ឍន៍សង្គមវិញ សព្វថ្ងៃក្រុមហ៊ុនបានសាងសង់ផ្លូវបែងចែងអនុតំបន់ និងផ្លូវមេព័ទ្ធព្រំដីក្រុមហ៊ុនដែលមានប្រវែងប្រមាណជា៨៩គ.ម ហើយប្រជាពលរដ្ឋអាចប្រើប្រាស់ផ្លូវទាំងនោះ ដោយជិះម៉ូតូធ្វើដំណើរបានយ៉ាងស្រួល រួមទាំងអ្នកភូមិឧបសម្ព័ន្ធស្រែនន និងយ៉ែផងដែរ ដែលកាលពីមុនគាត់អាចធ្វើដំណើរនៅក្នុងតំបន់នោះបានតាមតែរយៈគោយន្ត និងរទេះគោប៉ុណ្ណោះ ឃើញថាពួកគាត់អាចមានទំនាក់ទំនងជាមួយតំបន់ខាងក្រៅបានទូលំទូលាយជាងមុនច្រើន ក៏ដូចជាការធ្វើដំណើរទៅកាន់ទីប្រជុំជន និងមណ្ឌលសុខភាពជាដើម។ ចំពោះភូមិភ្លៀរ ក្រុមហ៊ុនមិនទាន់អភិវឌ្ឍទៅដល់ ព្រោះភូមិភ្លៀរនៅក្បែរអនុតំបន់ទី៤ ដូច្នេះនៅពេលដែលយើងអភិវឌ្ឍនៅអនុតំបន់ទី៤ យើងនឹងធ្វើការសាងសង់ផ្លូវដូចនៅអនុតំបន់ទី១ និងទី២ដែរ ពេលនោះភូមិភ្លៀរនឹងមានការងាយស្រួលក្នុងការធ្វើដំណើរតាមផ្លូវក្រុមហ៊ុនជាក់ជាមិនខាន។ បច្ចុប្បន្ន ក្រុមហ៊ុនរង់ចាំការអនុញ្ញាតពីក្រសួងកសិកម្ម ដើម្បីធ្វើការឈូសឆាយដាំដុះនៅអនុតំបន់ទាំងពីរនេះបន្តទៀត។

ចំពោះព្រៃទ្រនាប់ដងអូរ ក្រុមហ៊ុនបានរក្សាទុកតាមការកំណត់របស់រាជរដ្ឋាភិបាល។ រីឯកម្លាំងពលកម្មដែលកំពុងបំរើការងារនៅក្នុងក្រុមហ៊ុនមានបុគ្គលិកសរុបជាង ៨០នាក់ ចំណែកចំនួនពលករ គឺទាក់ទងទៅនឹងរដូវកាលនៃការដាំដុះដែលអាចមានរហូតដល់ជាង ៦០០នាក់។ ពលករម្នាក់អាចទទួលប្រាក់កម្រៃ ២០.០០០រៀលក្នុងមួយថ្ងៃ ដែលជាតម្លៃខ្ពស់ជាងគេនៅក្នុងតំបន់។

**លោកស្រី ហ៊ាន ជាវគុណ ជាតំណាង និងជាអ្នកសម្របសម្រួលរបស់អង្គការអាដហុក** បានលើកជាមតិពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងការងារមួយចំនួននៅក្នុងភូមិភ្លៀរថា៖ ប្រជាពលរដ្ឋនៅភូមិភ្លៀរចំនួន ១៩៧ គ្រួសារបានធ្វើពាក្យបណ្ដឹងទៅអង្គការអាដហុក សុំដីលិចទឹក ដីអ្នកតា តំបន់មានដើមថ្នាំ។ល។ និងសុំឲ្យទុកដីត្រង់អូរព្រីមផងដែរ។

**លោក វ៉ា ថន អភិបាលរងខេត្តក្រចេះ** មានមតិបំភ្លឺថា៖ ជាទូទៅ តាមគោលការណ៍របស់រាជរដ្ឋាភិបាល ពីផ្ទៃដីស្នើសុំរបស់អ្នកវិនិយោគ ត្រូវបានកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធរបស់ប្រជាពលរដ្ឋ ដីព្រៃទ្រនាប់ដងអូរចម្ងាយពី១០០ទៅ១៥០ម៉ែត្រ ព្រៃរក្សាទុកផ្សេងៗ ដីអ្នកតា ដីកប់ខ្មោច ដីមានសំណង់ប្រវត្តិសាស្ត្រ

Draft

។ល។និង។ល។ ដូចនេះយើងដែលជាស្ថាប័នជំនាញពាក់ព័ន្ធ ក៏ត្រូវពិនិត្យលើការអនុវត្តន៍របស់ក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ចនេះដែរ ថាតើគាត់បានអនុវត្តតាមកិច្ចសន្យាដែរឬទេ? ហើយការទាមទាររបស់ប្រជាពលរដ្ឋភូមិភ្លៀវ អាជ្ញាធរថ្នាក់ខេត្តក៏បានទៅចូលរួមដោះស្រាយចំនួន ៩លើកមកហើយដែរ ប៉ុន្តែក៏នៅមិនទាន់ដោះរួចដាច់ស្រេចជាស្ថាពរនៅឡើយ។ ដោយឡែក លើប្រធានបទការរៀបចំផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ក្នុងអង្គសិក្ខាសាលាថ្ងៃនេះ គួរធ្វើការពិគ្រោះយោបល់គ្នា និងសម្រេចជាអនុសាសន៍មួយ ដើម្បីឲ្យខាងក្រុមហ៊ុនប្រឹក្សាមានលទ្ធភាពធ្វើការងារនេះបន្តទៀត។

**លោក ស៊ឹង ផល មេឃុំកន្ទួត** មានមតិចូលរួមថាៈ ពិនិត្យលើស្ថានភាពជាក់ស្តែង ភូមិស្រែននមានបញ្ហាទឹកស្អាតនៅក្រោមបន្ទាត់តម្រូវការ ហើយនិងកង្វះខាតផ្សេងៗទៀត ប៉ុន្តែចំពោះមុខ គួរជួយអ្នកភូមិស្រែននូវអណ្តូងទឹកស្អាតមួយ ដើម្បីជួយកាត់បន្ថយអត្រាជម្ងឺក្រពះពោះវៀនមួយចំនួនដែលអាចបណ្តាលមកពីការប្រើប្រាស់ជី និងថ្នាំគីមីទៅលើដំណាំរបស់ក្រុមហ៊ុន និងជួយសម្រួលដល់ការរស់នៅរបស់ពួកគាត់ឲ្យបានមួយចំណែកទៀត ពិសេសគឺដើម្បីជាការលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងភូមិស្រែនន ដែលភាគច្រើនបានចូលធ្វើជាពលករ-កម្មកររបស់ក្រុមហ៊ុនក្នុងអត្រាច្រើនជាងភូមិដទៃទៀតផង។

**លោក អ៊ិត ញ៉ុញ មេឃុំភ្លៀវ** មានសំណើថាៈ ភូមិភ្លៀវជាភូមិមួយនៅដាច់ស្រយាលជាងគេក្នុងចំណោមភូមិដទៃទៀតនៃឃុំថ្មី។ ការធ្វើដំណើរពីភូមិនេះទៅកាន់មណ្ឌលសុខភាពគឺមានសភាពពិបាកខ្លាំងណាស់ (១៧គ.ម) ទំរាំមកដល់ភូមិស្វាយជ្រុំដែលមានផ្លូវចោចក្នុងឃុំថ្មី។ ប្រជាពលរដ្ឋចង់បានប៉ុស្តិ៍សុខភាពមួយ ឬផ្លូវលំមួយសម្រួលដល់ការធ្វើដំណើរ ពិសេសនៅពេលមានជម្ងឺឈឺថ្កាត់ ឬស្ត្រីត្រូវឆ្លងទន្លេ។

**លោក យស ភារី ប្រធានអង្គការ CED ប្រចាំខេត្តក្រចេះ** បានមានមតិថាៈ ដោយសារតែប្រជាពលរដ្ឋរស់នៅក្នុងតំបន់នេះ ភាគច្រើនជាជនជាតិដើមភាគតិច ដូច្នេះគួរពិនិត្យជាក់ស្តែងលើផលវិបាកមួយចំនួនដែលអាចកើតមានពីការផ្លាស់ប្តូរមុខរបររបស់ពួកគាត់ លើសពីនេះទៅទៀតគួរតែជួយសម្រួលដល់ការប្រើប្រាស់ដីរបស់ពួកគាត់ផងដែរ។

**លោក វ៉ា ថន អភិបាលរងខេត្តក្រចេះ** មានមតិបំភ្លឺថាៈ ជាគោលការណ៍ មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពអាចបង្កើតបានដោយត្រូវសមមាត្រទៅនឹងចំនួនប្រជាពលរដ្ឋក្នុងតំបន់នោះ ម្យ៉ាងទៀតមូលនិធិរបស់ក្រុមហ៊ុននេះពិតជាមិនមានលទ្ធភាពបង្កើតបាន ព្រោះត្រូវការថវិកាច្រើនជាងនេះ នេះមិនទាន់គិតពីបុគ្គលិក ឬគ្រូពេទ្យប្រចាំផង។ ប្រជាពលរដ្ឋ ពិសេសបងប្អូនជនជាតិដើមភាគតិច ត្រូវតែផ្លាស់ប្តូរទំលាប់ចាស់ពីការពឹងផ្អែកលើការអាស្រ័យផលធនធានធម្មជាតិ ទៅជាការធ្វើប្រពលវប្បកម្មកសិកម្មលើដីស្រែចម្ការដែលពួកគាត់មានស្រាប់ ព្រោះធនធានធម្មជាតិកំពុងតែរេចរឹលទៅៗ ហើយក៏កំពុងឈានទៅរកការបាត់បង់ផងដែរ។ ហេតុដូចនេះ ទើបរាជរដ្ឋាភិបាលស្វែងរកការវិនិយោគ ដែលអាចផ្តល់នូវការធានានូវកំរិតជីវភាពប្រជាពលរដ្ឋឲ្យបានសមស្របមួយក្នុងតំបន់គំរោង និងអាចរក្សាលំនឹងគុណភាពបរិស្ថានបាន ជំនួសឲ្យការបំផ្លាញធនធានធម្មជាតិដោយអនាធិបតេយ្យ ហើយប្រជាពលរដ្ឋនៅតែមានជីវភាពក្រីក្រដដែលនោះ។ បច្ចុប្បន្ន អាជ្ញាធរខេត្តខិតខំធ្វើការដោះស្រាយបញ្ហាដីធ្លីច្រើនណាស់ ទៅតាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួន ដើម្បីជួយសម្រួល និងផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត។

Draft

ដើម្បីជួយសម្រួលដល់ការរស់នៅ និងការគាំពារសុខភាពរបស់ប្រជាពលរដ្ឋក្នុងភូមិស្រែនន អង្គសិក្ខាសាលាបានពិនិត្យ និងសម្រេចជួយផ្តល់អណ្តូងទឹកមួយដល់ពួកគាត់ក្នុងជំហានដំបូង នៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍របស់ក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូនេះ។

**លោក សុខ គីរីរតន៍ ប្រធានមន្ទីរធនធានរ៉ែ និងថាមពល** មានមតិថាៈ នៅលើដីសម្បទានសេដ្ឋកិច្ចដែលមិនមានការឈូសឆាយកាយរករ៉ែទេនោះ មិនតម្រូវឲ្យមានការសិក្សាវាយតម្លៃផលប៉ះពាល់ឡើយ លើកលែងតែមានការកាយរករ៉ែធ្វើអាជីវកម្ម ទើបតម្រូវឲ្យមានការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ដូច្នេះចំពោះគម្រោងនេះ គឺគ្មានបញ្ហាអ្វីទាក់ទងទៅនឹងបញ្ហាធនធានធម្មជាតិក្រោមដីឡើយ។

**លោក ខាន់ ប៊ុនសេង អនុប្រធានមន្ទីរការងារ** បានមានមតិថាៈ ការវិនិយោគតែងកាត់បន្ថយដីសម្រាប់ដើររបស់ប្រជាពលរដ្ឋ សត្វព្រៃ និងសត្វពាហនៈ ដូចនេះជំនួសឲ្យការបាត់បង់នេះ ត្រូវបំពេញមកវិញនូវអ្វីដែលប្រជាពលរដ្ឋក្នុងតំបន់នោះត្រូវការ។

**បណ្ឌិត លីសុពណ៌-មុនី** មានមតិស្វាគមន៍ចំពោះមតិចូលរួមរបស់វាគ្មិនទាំងអស់ និងឆ្លើយតបថាៈ មុននឹងធ្វើការបកស្រាយឆ្លើយតប ខ្ញុំចង់លើកឡើងនូវសុភាសិតមួយមកធ្វើការពិចារណាទាំងអស់គ្នាថា ការឲ្យត្រីគាត់ហូប និងការបង្រៀនឲ្យគាត់ចេះស្ទូចត្រី មួយណាប្រសើរជាង? យើងដឹងទាំងអស់គ្នាថា ធនធានធម្មជាតិរបស់យើងកាន់តែហិនហោចទៅៗជាលំដាប់ ជំនួសឲ្យការប្រើប្រាស់ធនធានធម្មជាតិដែលកំពុងរេចរឹល យើងគួរតែព្យាយាមណែនាំពួកគាត់ឲ្យប្រើប្រាស់លទ្ធភាពដែលមាន ហើយដែលអាចធ្វើបាន ដោយធ្វើការអភិវឌ្ឍន៍គ្រួសារគំរូ សម្រាប់ឲ្យប្រជាពលរដ្ឋផ្សេងទៀតស្វែងយល់ និងអនុវត្តតាមក្រោយពីការមើលឃើញនូវលទ្ធផលវិជ្ជមាន។ ក្រោយពេលដែលក្រុមហ៊ុនទទួលបានការអនុញ្ញាត ក្រុមហ៊ុននឹងធ្វើការឈូសឆាយនៅអនុតំបន់ទី ៣ និងទី ៤ ហើយនឹងមានការសាងសង់ផ្លូវលំបែងចែកអនុតំបន់ និងផ្លូវមេព័ទ្ធព្រំដីក្រុមហ៊ុន ដូចនេះចម្ងាយពីភូមិឡៀវទៅដីក្រុមហ៊ុនមានចម្ងាយនៅសល់ប្រមាណជា ៣-៤គ.ម ប៉ុណ្ណោះ ពេលនោះពួកគាត់អាចធ្វើដំណើរតាមផ្លូវក្រុមហ៊ុនភ្ជាប់ទៅកាន់ផ្លូវជាតិបាន។

ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលជាពលករ និងកម្មកររបស់ក្រុមហ៊ុនក្នុងការមានសតិអារម្មណ៍ និងកង្វល់លើបញ្ហាការសិក្សារបស់កូនចៅរបស់ពួកគាត់ និងដើម្បីទាក់ទាញពួកគាត់កុំឲ្យធ្វើចំណាកស្រុកទៅរកការងារនៅកន្លែងផ្សេង ដែលនឹងបង្កជាផលលំបាកក្នុងការស្វែងរកកម្លាំងពលកម្មនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូរយៈពេលវែងរបស់ខ្លួនផងនោះ ក្រុមហ៊ុនមានជម្រើសតែមួយគត់ គឺត្រូវសាងសង់នូវសាលារៀនសម្រាប់កូនចៅរបស់ពលករ-កម្មករក្រុមហ៊ុន មណ្ឌលសុខភាព រួមទាំងការផ្តល់នូវសេវាសាធារណៈផ្សេងៗទៀតនៅក្នុងតំបន់ ដែលប្រជាពលរដ្ឋយើងអាចទៅរកសេវាទាំងអស់នោះបានក្នុងពេលអនាគត។ ដូច្នេះ យើងគួរពិចារណាយ៉ាងល្អិតល្អន់ទៅលើការរៀបចំផែនការប្រើប្រាស់មូលនិធិនេះឲ្យបានសមស្របតាមតម្រូវការ។ យើងត្រូវពិចារណាទាំងអស់គ្នាថា យើងគួរបង្រៀនពួកគាត់ឲ្យចេះស្ទូចត្រី ឬយើងនៅតែបន្តឲ្យត្រីទៅពួកគាត់ហូបរហូត។

យើងកំពុងតែជ្រើសរើសផ្លូវឲ្យពួកគាត់ដើរទៅរកការអភិវឌ្ឍន៍ជាក់ស្តែងមួយ ជំនួសឲ្យជីវិតអាស្រ័យលើធនធានធម្មជាតិ ដែលពឹងផ្អែកលើធម្មជាតិទាំងស្រុង និងគ្មានអនាគតភាព។ ដូចនេះពួកគាត់ចាំបាច់ត្រូវផ្លាស់ប្តូរទំលាប់នៃការរស់នៅរបស់ខ្លួន។ យ៉ាងណាមិញ វិធានការជ្រើសរើសគ្រួសារគំរូចំនួន ០៩ ក្នុងមួយឆ្នាំ

សម្រាប់ផែនការអភិវឌ្ឍន៍សហគមន៍នៅចំណុចចាប់ផ្តើមនេះ នឹងអាចទទួលបានជោគជ័យ ហើយក្លាយទៅជាវិធានការគំរូសម្រាប់ប្រជាពលរដ្ឋដទៃទៀតអនុវត្តតាម ហើយឈានទៅរកការផ្លាស់ប្តូរទំលាប់ចាស់របស់ពួកគាត់។

ទាក់ទិននឹងការប្រើប្រាស់មូលនិធិដែលមានទឹកប្រាក់ ២៥.០០០ដុល្លាអាមេរិក/ឆ្នាំ សម្រាប់កម្មវិធីស្តារគុណភាពបរិស្ថាន យើងអាចប្រជុំពិភាក្សាគ្នា ជ្រើសរើសយកថ្ងៃណាមួយ ជាឧទាហរណ៍ នៅថ្ងៃបុណ្យវក្ខទិវា យើងអាចនាំគ្នាចុះទៅដាំកូនឈើនៅតាមដងអូរដែលមានព្រៃរេចរឹល ហើយកូនឈើទាំងនោះ នឹងត្រូវបានផ្តល់ជូនពីក្រុមហ៊ុនវិនិយោគ ហើយក្រៅពីនេះនៅមានសកម្មភាពស្តារបរិស្ថានមួយចំនួនទៀត ដែលយើងនឹងរៀបចំជាកម្មវិធីបន្តបន្ទាប់នៅពេលអនាគតទៀតផងដែរ។

**លោក សួន ញ៉ាក អភិបាលស្រុកចិត្របុរី** បានមានមតិៈ កន្លងមកក៏មានប្រជាកសិករយើងប្រកបមុខរបរដាំដំណាំកសិកម្មផ្សេងៗ រីឯដំណាំស្វាយចន្ទីនេះទៀតសោតក៏ពួកគាត់បានដាំរួចមកហើយដែរ ប៉ុន្តែផលិតផលដែលប្រមូលបាន គឺគ្មានទីផ្សារទាល់តែសោះ។ ឆ្លងកាត់បទពិសោធន៍ជាក់ស្តែង ប្រជាកសិករមានជីវភាពពឹងផ្អែកលើផ្នែកកសិកម្ម ពិសេសការធ្វើស្រែចម្ការ និងចិញ្ចឹមសត្វ។ ពួកគាត់អាចមានលទ្ធភាពទិញម៉ូតូជិះបាន ក៏ដោយសារការលក់គោ លក់ក្របីប៉ុណ្ណោះ ប្រសិនបើមានលទ្ធភាពចិញ្ចឹម ក្នុងមួយឆ្នាំៗ ពួកគាត់អាចលក់បាន ៣-៤លាន រៀលសម្រាប់គោមួយក្បាល ឬ៤-៥លានរៀលសម្រាប់ក្របីមួយក្បាល ដូច្នេះគួរជួយពួកគាត់ក្នុងមុខរបរទាំងពីរនេះវិញ។

**លោក ម៉ៅ វិចិត្រ អនុប្រធានមន្ទីរកសិកម្ម** មានមតិថាៈ សូមគាំទ្រចំពោះយោបល់ចិញ្ចឹមសត្វគោក្របីនេះ ចង់បានមតិពីប្រជាពលរដ្ឋតាមភូមិ និងឃុំគោលដៅបន្ថែមទៀត។

**លោក វ៉ា ថន អភិបាលរងខេត្តក្រចេះ** មានមតិយល់ស្របថាៈ ត្រូវរៀបចំក្រុមការងារមួយទៅសាកសួរប្រជាពលរដ្ឋឲ្យបញ្ចេញមតិផ្ទាល់ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការពិនិត្យនិងសម្រេចឆ្លើយតបទៅនឹងប្រធានបទនេះ។ ប្រជាពលរដ្ឋតាមរយៈអាជ្ញាធរភូមិឃុំត្រូវធ្វើសំណើមកមន្ទីរជំនាញនៃស្ថាប័នពាក់ព័ន្ធ និងបញ្ជូនមកអាជ្ញាធរខេត្តដើម្បីពិនិត្យលទ្ធភាពបន្ត។

**លោក ប៉ែន លីណាត នាយករដ្ឋបាលសាលាខេត្ត** បានមានមតិៈគួរផ្តល់អណ្តូងទឹកប្រើប្រាស់ដោយបន្ធូរសូឡាសម្រួលដល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ មានទឹកពួកគាត់អាចប្រើប្រាស់សម្រាប់ពង្រីកការដាំដុះនៅជុំវិញផ្ទះបាន។

**លោក មាន មានិត មន្ត្រីគំរោងតំណាងអង្គការ OXFAM** បានចូលរួមមតិថាៈ ក្រុមការងាររបស់ពួកគាត់កំពុងអនុវត្តគំរោងបង្កើតស្ថានីយផលិតទឹកសុទ្ធដែលអាចផលិតទឹកសុទ្ធ ៤០០០លីត្រក្នុងមួយថ្ងៃ ដោយត្រូវការថវិកា ៦០.០០០-៨០.០០០ដុល្លាសម្រាប់ស្ថានីយមួយ។ សូមបញ្ជាក់ថា ពួកគាត់អាចមានលទ្ធភាពលក់ទឹកសុទ្ធក្នុងតម្លៃថោកក្នុងមូលដ្ឋានរបស់ខ្លួន សម្រាប់ទុកប្រើប្រាស់ក្នុងការជួសជុល និងដំណើរការឲ្យមាននិរន្តរភាពទៀតផង។ ដើម្បីរៀបចំបង្កើតស្ថានីយមួយក្នុងភូមិគោលដៅ តើក្រុមហ៊ុនអាចមានលទ្ធភាពឲ្យខ្ចីមូលនិធិសម្រាប់រយៈពេល ៣-៤ឆ្នាំជាមុនសរុបតែម្តងបានដែរឬទេ ?

**បណ្ឌិត លីសុពណ៌-មុនី** មានមតិស្វាគមន៍ចំពោះមតិចូលរួមនេះ និងឆ្លើយតបថាៈ យោបល់នេះគឺជាយោបល់មួយល្អណាស់។ ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស នឹងកត់ត្រាទុកនូវគំនិតនេះ ហើយ

Draft

នឹងពិភាក្សាជាមួយក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿកអំពីលទ្ធភាពនៃការខ្ចីថវិកាមូលនិធិ ៣-៤ឆ្នាំជាមុន សរុបតែម្តងបានដែរឬមួយយ៉ាងណា សម្រាប់គម្រោងនេះ។

**លោក អ៊ុំ សុភ័ណ្ឌ ប្រធានការិយាល័យអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃក្រសួងបរិស្ថាន** បានលើកឡើងថា ស្មារតីនៃអង្គសិក្ខាសាលានេះ នឹងត្រូវបានពិនិត្យឡើងវិញ នៅពេលប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងវាយតម្លៃរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញសម្រាប់ក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) នៅលើដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក (អេស ប៊ី ខេ)។

**អង្គសិក្ខាសាលាបានផ្តល់ជាអនុសាសន៍ដូចខាងក្រោម៖**

- ដើម្បីជួយសម្រួលដល់ការរស់នៅ និងការគាំពារសុខភាពរបស់ប្រជាពលរដ្ឋក្នុងភូមិស្រែនន អង្គសិក្ខាសាលាបានពិនិត្យ និងសម្រេចជួយផ្តល់អណ្តូងទឹកមួយដល់ពួកគាត់ក្នុងជំហានដំបូងនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ របស់ក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូ ដូទីសាយហ្គូន-ប៊ិញហឿកនេះ។
- ចំពោះផែនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ សម្រាប់ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ តាមរយៈការផ្តល់នូវជម្រើសនៃការរកប្រាក់ចំណូលគ្រួសារ ដើម្បីបង្កើនកម្រិតជីវភាពរបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធក្នុងតំបន់គម្រោង ប្រជាពលរដ្ឋខ្លួនឯងត្រូវលើកជាសំណើដែលជាលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់គ្នានៅថ្នាក់មូលដ្ឋាន និងផែនការអភិវឌ្ឍន៍ឃុំមកក្រុមហ៊ុន តាមរយៈអាជ្ញាធរភូមិ ឃុំ ស្រុក ខេត្ត និងមន្ទីរពាក់ព័ន្ធ។ ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក មានភារៈកិច្ចទទួលនូវការផ្តល់មូលនិធិអភិវឌ្ឍន៍សហគមន៍របស់ខ្លួនចំនួន ២០.០០០ដុល្លាអាមេរិកក្នុងមួយឆ្នាំ និងការងារបច្ចេកទេស។ ចំណែកការត្រួតពិនិត្យ តាមដាន និងវាយតម្លៃជាភារៈកិច្ចរបស់ក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស។
- ការប្រើប្រាស់មូលនិធិដែលមានទឹកប្រាក់ ២៥.០០០ដុល្លាអាមេរិក/ឆ្នាំ សម្រាប់កម្មវិធីស្តារគុណភាពបរិស្ថាន នឹងត្រូវប្រព្រឹត្តទៅតាមរយៈការប្រជុំពិភាក្សាគ្នារវាងអាជ្ញាធរខេត្ត មន្ទីរពាក់ព័ន្ធ ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក និងក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស ដើម្បីជ្រើសរើសយកពេលវេលាសមស្រប និងសកម្មភាពស្តារបរិស្ថានណាមួយ (ឧទាហរណ៍ ដូចជាការដាំកូនឈើនៅតាមដងព្រែកទេដែលរេចរឹលជាដើម) ដើម្បីអនុវត្តបន្តរៀងទៅ។

អង្គសិក្ខាសាលានេះបានបញ្ចប់នៅម៉ោង ដប់ពីរ និងសាមសិបនាទីថ្ងៃត្រង់ នាថ្ងៃខែនិងឆ្នាំដដែល។ ក្រោមបរិយាកាសស្និទ្ធស្នាល និងកក់ក្តៅបំផុត។

## ៦.២.៤.២ ការពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធទៅនឹងដីសម្បទានសេដ្ឋកិច្ចនៅឃុំថ្មី

២. កាលពីថ្ងៃទីប្រាំមួយ ខែតុលា ឆ្នាំពីរពាន់ដប់បួន វេលាម៉ោងប្រាំបួនព្រឹក នៅសាលាឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ មានរៀបចំការពិភាក្សាពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធទៅនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហឿក ជាមួយប្រជាពលរដ្ឋក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ។

ការពិគ្រោះយោបល់នេះ មានការចូលរួមពីលោកអភិបាលរងស្រុកចិត្របុរី លោកអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ លោកមេឃុំថ្មី ជំទប់ទី១ ជំទប់ទី២ មេភូមិ អនុភូមិប្បៀរ ភូមិស្វាយជ្រុំ ភូមិថ្មី ភូមិត្នោត និងភូមិឧបសម្ព័ន្ធយ៉ៃ ប្រជាពលរដ្ឋចំនួនបីនាក់ក្នុងមួយភូមិៗ នាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស តំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហឿក ព្រមទាំងបុគ្គលិកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស សរុបចំនួន ៣៥នាក់ (ឧបសម្ព័ន្ធ៦-១ តារាង៣, ឧបសម្ព័ន្ធ៦-២ រូបភាព)។ សមាសភាពអ្នកចូលរួមមាន៖

**តារាង ៦-៣៖ សមាសភាពចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធទៅនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ) ជាមួយប្រជាពលរដ្ឋក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ**

| លរ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន |
|---|---|---|---|---|
| ១ | អ៊ួង សម្បត្តិ | ប្រ | អភិបាលរង | ស្រុកចិត្របុរី |
| ២ | មុំ ខាំ | ប្រ | មេឃុំ | ឃុំថ្មី |
| ៣ | យឹម ម៉ៅ | ប្រ | ជំទប់ទី១ | ឃុំថ្មី |
| ៤ | ម៉ឹង ស្រេន | ប្រ | ជំទប់ទី២ | ឃុំថ្មី |
| ៥ | គាំ គឿន | ប្រ | ស្មៀន | ឃុំថ្មី |
| ៦ | សេន អឿន | ប្រ | មេភូមិ | ភូមិថ្មី |
| ៧ | ហ៊ិង វាសនា | ស្រ | មេភូមិ | ភូមិត្នោត |
| ៨ | អ៊ិត ញ៉ញ | ប្រ | មេភូមិ | ភូមិប្បៀរ |
| ៩ | តាំង ពេន | ប្រ | មេភូមិ | ភូមិស្វាយជ្រុំ |
| ១០ | វ៉ន់ ក្រួច | ប្រ | អនុភូមិ | ភូមិប្បៀរ |
| ១១ | ហ៊ី ពៅ | ប្រ | ជំនួយការ | ភូមិស្វាយជ្រុំ |
| ១២ | យិន រឿន | ស្រ | ប្រជាជន | ភូមិត្នោត |
| ១៣ | បាក់ ធត | ប្រ | ប្រជាជន | ភូមិត្នោត |
| ១៤ | សៀង ឌុន | ប្រ | ប្រជាជន | ភូមិត្នោត |
| ១៥ | ជាប់ វ៉ា | ប្រ | ប្រជាជន | ភូមិប្បៀរ |
| ១៦ | ស៊ន ញឹក | ប្រ | ប្រជាជន | ភូមិថ្មី |
| ១៧ | ខាំ ម៉ុង | ប្រ | ជំនួយការស្មៀន | ភូមិថ្មី |
| ១៨ | ជាម វុទ្ធី | ប្រ | សមាជិក | ភូមិថ្មី |
| ១៩ | បេត ម៉េត | ប្រ | ប្រធានសហគមន៍ព្រៃឈើ | ភូមិថ្មី |
| ២០ | សូ គឿន | ប្រ | ប្រជាជន | ភូមិថ្មី |
| ២១ | ផៃ កែ | ប្រ | ប្រជាជន | ភូមិប្បៀរ |
| ២២ | ប្រាយ ទិត្យ | ប្រ | ប្រជាជន | ភូមិស្វាយជ្រុំ |
| ២៣ | គុត យន | ប្រ | ប្រជាជន | ភូមិស្វាយជ្រុំ |

Draft

| | | | | |
|---|---|---|---|---|
| ២៤ | ហ៊ិន រិសេស | ប្រ | ប្រធានសហគមន៍ | ក្រុមហ៊ុន DTSG-BP |
| ២៥ | អ៊ឹម សុធី | ប្រ | តំណាងក្រុមហ៊ុន | ក្រុមហ៊ុន DTSG-BP |
| ២៦ | ធៀង តេង | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ២៧ | កែវ សុវណ្ណ | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ២៨ | ផាន់ វណ្ណៈ | ប្រ | ជំនួយការ | ក្រុមហ៊ុន DTSG-BP |
| ២៩ | នៀល ពៅ | ប្រ | ប្រជាជន | ភូមិស្វាយជ្រុំ |
| ៣០ | ផុន សាន | ប្រ | ប្រជាជន | ភូមិម្លៀរ |
| ៣១ | ហាង ចំរើន | ប្រ | PC | KBSC |
| ៣២ | ជួន សំអាត | ស្រ | PO | CED |
| ៣៣ | ម៉ៅ សុខជា | ប្រ | អនុប្រធានមន្ទីរ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ៣៤ | បណ្ឌិត លី សុពណ៌-មុនី | ប្រ | នាយក | ក្រុមហ៊ុន ETS |
| ៣៥ | សយ សុខដុម | ប្រ | បុគ្គលិក | ក្រុមហ៊ុន ETS |

លោក មុំ ខាំ មេឃុំថ្មី បានមានមតិបើកការពិភាក្សាពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក ជាមួយប្រជាពលរដ្ឋភូមិម្លៀរ ភូមិស្វាយជ្រុំ ភូមិថ្មី ភូមិក្រសាំង ភូមិត្នោត និងភូមិឧបសម្ព័ន្ធយ៉ែរបស់ភូមិត្នោត។ លោកបានសង្ខេបប្រវត្តិដីសម្បទានសេដ្ឋកិច្ចនេះថា ចាប់តាំងពីឆ្នាំ ២០០៦មក រហូតមកទល់នឹងឆ្នាំ ២០១២ មិនដែលមានបញ្ហាទំនាស់អ្វីឡើយ។ ដោយឡែកពីឆ្នាំ ២០១២ មកទល់នឹងបច្ចុប្បន្ន បានកើតមានបញ្ហាដែលដោះស្រាយមិនទាន់ចេញ គឺបញ្ហាដីដែលប្រជាពលរដ្ឋនៅភូមិម្លៀរទាមទារបន្ថែម។ លើសពីនេះទៅទៀត ថ្មីៗនេះមានការរារាំងគ្រឿងចក្ររបស់ក្រុមហ៊ុនមិនឲ្យជីកកាយចង្អូរព្រំដីនៅភូមិស្វាយជ្រុំ និងការយឺតយ៉ាវនៃការអនុវត្តន៍កិច្ចសន្យារបស់ក្រុមហ៊ុនជូនប្រជាពលរដ្ឋ។

បន្ទាប់ពីលោក មុំ ខាំ មានមតិផ្តើមបើកការពិភាក្សារួចមក **លោកបណ្ឌិត លី សុពណ៌-មុនី នាយកក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក ស៊ីវែ** បានមានមតិក្នុងន័យសម្របសម្រួលទំនាក់ទំនងរវាងប្រជាពលរដ្ឋក្នុងតំបន់ជាមួយក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក ថាៈ ភាគីទាំងពីរគួរសម្របសម្រួលគ្នាឲ្យបានឆាប់រហ័ស ដោយមានចេតនាសម្បទានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យគំរោងវិនិយោគអភិវឌ្ឍន៍នេះមានដំណើរការទៅយ៉ាងរលូន ហើយប្រជាពលរដ្ឋនឹងអាចទទួលបាននូវផលវិជ្ជមានសមស្របមួយ ជួយជំរុញការអភិវឌ្ឍន៍សហគមន៍ឲ្យបានលឿនទៅមុខផងដែរ។

លោក មេឃុំថ្មី មុំ ខាំ បានមានមតិបន្ថែមថាៈ ការដោះស្រាយភាពចម្រូងចម្រាស់ក្នុងបញ្ហាដីពាក់ព័ន្ធរវាងក្រុមហ៊ុនជាមួយប្រជាពលរដ្ឋ មានជាច្រើនលើកច្រើនសារហើយ ប៉ុន្តែនៅមិនទាន់បានបញ្ចប់នៅឡើយទេ ក្នុងនោះមានទាំងបញ្ហាកាយចង្អូរធ្វើព្រំដីរបស់ក្រុមហ៊ុនផងដែរ។ ប្រជាពលរដ្ឋមិនចង់ឲ្យក្រុមហ៊ុនមកកាយចង្អូរធ្វើព្រំដីក្បែរក្លីស្រែចម្ការរបស់ពួកគាត់ ដោយលើកហេតុផលថា នឹងអាចមានគ្រោះថ្នាក់ដល់គោក្របីរបស់ពួកគាត់ ហើយម្យ៉ាងទៀតនៅពេលដើមកៅស៊ូធំនឹងចោលម្លប់លើស្រូវរបស់ពួកគាត់ទៀតផង។

**លោកមេភូមិស្វាយជ្រុំ ស៊្រុ រាក់** បានមានមតិលើកឡើងថា៖ បញ្ហាដីនៅភូមិស្វាយជ្រុំ បានដោះស្រាយប្រមាណ ៩០% ហើយ។ ចំណុចទីតាំងដែលមិនទាន់ដោះស្រាយ គឺនៅត្រង់ចំណុចអូរដា និងអូរពក លើដីប្រមាណ ១៨៧ហ.ត ដោយសារប្រជាពលរដ្ឋមិនទាន់យល់ព្រមឲ្យក្រុមហ៊ុនកាយចង្អូរធ្វើព្រំដី។ ប្រជាពលរដ្ឋក្នុងភូមិស្វាយជ្រុំបានព្រមព្រៀងគ្នាជាមួយភាគីក្រុមហ៊ុន ចុះធ្វើការវាស់វែងព្រំដីរបស់ក្រុមហ៊ុនដែរ ប៉ុន្តែមិនទាន់បានលទ្ធផលនៅឡើយ ដោយសារមានប្រជាពលរដ្ឋខ្លះនិយាយថា បានខិតចូលដីរបស់គាត់។

**លោកមេភូមិឡៀរ អ៊ិត ញ៉ុញ** មានមតិថា៖ បញ្ហាជាមួយក្រុមហ៊ុននៅក្នុងភូមិឡៀរ បានដោះស្រាយចំនួន ៣លើកមកហើយ តែនៅមិនទាន់បានស្ងប់ស្ងាត់ ដោយសារប្រជាពលរដ្ឋទាមទារដីបន្ថែមទៀតសំរាប់ប្រជាពលរដ្ឋក្នុងភូមិ។ ក្រៅពីក្រសួងកសិកម្មកាត់ដី ១៨០ ហ.ត ឲ្យហើយ នៅមានដី ៥៤៥,៤២ ហ.ត ដែលពួកគាត់ទាមទារឲ្យកាត់ទុកឲ្យបន្ថែមទៀត ពុំនោះសោតមានប្រជាពលរដ្ឋ ៤០% រៀបចំញត្តិតវ៉ាទាមទារដីបន្ថែមទៀតនេះទៅថ្នាក់លើ ទោះបីរូបលោកបានប្រឹងប្រែងធ្វើការសម្របសម្រួលយ៉ាងណាក៏ដោយ ដោយសារមានមេខ្យល់ជាអ្នកនាំធ្វើការតវ៉ាទាមទារដីបន្ថែម។ បច្ចុប្បន្ននេះ មានរហូតដល់អ្នកកាសែត និងអង្គការមួយចំនួនបានចូលទៅសួរនាំដល់ភូមិទៀតផង។

**មេភូមិឧបសម្ព័ន្ធយ៉ៃ លោកស្រី យិន រឿន** បានចូលរួមមតិថា មកទល់នឹងពេលនេះចំណុចយ៉ៃ មិនមានបញ្ហាអ្វីជាមួយក្រុមហ៊ុនទេ គ្រាន់តែសុំទុកដី និងធ្វើផ្លូវសំរាប់ធ្វើដំណើរចេញចូលប្រវែង ១០០ម៉ែត្រ ប៉ុណ្ណោះ។

លោក **អ៊ឹម សុធី** តំណាងឲ្យក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហ្សៀក បានមានប្រសាសន៍ថា៖ ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហ្សៀក បច្ចុប្បន្នជាក្រុមហ៊ុនវិនិយោគអាមេរិក ដែលបានផ្ទេរបន្តពីក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហ្សៀក ពីមុនមក ដូច្នេះមិនមែនជាក្រុមហ៊ុនវៀតណាមទៀតទេ គ្រាន់តែឈ្មោះនៅដដែលប៉ុណ្ណោះ។ លោកបានលើកបង្ហាញអំពីផលប្រយោជន៍នៃការវិនិយោគ ក្នុងនោះមាន៖ អាទិភាពការងារសំរាប់ប្រជាពលរដ្ឋធ្វើជាពលករក្នុងក្រុមហ៊ុន ការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា ផ្លូវលំ ប៉ុស្តិ៍សុខភាពប្រចាំក្រុមហ៊ុន និងការបង់ពន្ធចូលរដ្ឋជាដើម។ លោកបានសំណូមពរឲ្យប្រជាពលរដ្ឋមានការយោគយល់ និងចូលរួមធ្វើសម្បទានទៅវិញទៅមកក្នុងការដោះស្រាយទំនាស់ ដើម្បីធ្វើការអភិវឌ្ឍន៍ក្នុងតំបន់នេះឲ្យបានលឿន និងទទួលបានជោគជ័យ។ ក្រុមហ៊ុនមិនដែលរំលោភលើដីប្រជាពលរដ្ឋទេ ផ្ទុយទៅវិញ ក្រុមហ៊ុនបាន និងកំពុងធ្វើសម្បទានយ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងការដោះស្រាយបញ្ហាទំនាស់ផ្សេងៗ ទាំងក្នុង និងក្រៅក្រុមហ៊ុន។ ប៉ុន្តែការយោគយល់ និងការធ្វើសម្បទានរបស់ក្រុមហ៊ុន ពិតជាមានព្រំដែន ហើយការទាមទារដីពីក្រុមហ៊ុនដែលមិនសមស្រប ក្រុមហ៊ុនពិតជាមិនអាចទទួលយកបាន។ ត្រង់ចំណុចនេះហើយដែលរូបខ្ញុំដែលជាពលរដ្ឋខ្មែរមួយរូបដែរ មានការព្រួយបារម្ភក្រែងលោក្រុមហ៊ុននេះយល់ថា មានកត្តាជាច្រើនដែលអយុត្តិធម៌សំរាប់ក្រុមហ៊ុន និងដោយសារតែមានបញ្ហារាំងស្ទះមិនចេះចប់មិនចេះហើយ ធ្វើឲ្យគេសំរេចចិត្តដកទុនវិនិយោគត្រឡប់ទៅវិញ នោះគឺជាការសោកស្តាយបំផុតសំរាប់ប្រជាពលរដ្ឋកម្ពុជា។ រីឯការយឺតយ៉ាវចំពោះការសន្យារបស់ក្រុមហ៊ុនដែលមិនទាន់បានបំពេញ គឺដោយសារក្រុមហ៊ុនមានការមមាញឹកក្នុងការដាំកៅស៊ូឲ្យបានទាន់ពេលវេលានៅរដូវវស្សា។ ចំពោះការអនុវត្តនូវកិច្ចសន្យានេះ ក្រុមហ៊ុននឹងបំពេញនៅរដូវប្រាំង។

Draft

**លោកបណ្ឌិត លី សុពណ៌-មុនី** បានជំរាបជូនប្រជាពលរដ្ឋថា៖ ការកាន់កាប់ដីនៅកន្លែងផ្សេង ក្រោយពេលក្រុមយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ ហ៊ុន សែន បានចុះវាស់វែងហើយនោះ គឺជាការខុសច្បាប់។ នៅលើរាល់ទីតាំងដែលចុះធ្វើការ ក្រុមហ៊ុនត្រូវមានកាន់ GPS ដើម្បីធ្វើការបញ្ជាក់ឲ្យបានច្បាស់អំពីចំណុចព្រំដីដោយមានចំណុចនិយាមកាកំណត់ត្រឹមត្រូវ ហើយក្រុមហ៊ុនក៏ត្រូវប្រញាប់ប្រញាល់ចុះបញ្ជីដីធ្លីរបស់ក្រុមហ៊ុនឲ្យបានឆាប់រហ័សផងដែរ។

**លោក អ៊ឹង សម្បត្តិ** អភិបាលរងស្រុកចិត្របុរីបានផ្តល់យោបល់ថា៖ ប្រជាពលរដ្ឋគួរធ្វើសម្បទានទៅវិញទៅមកជាមួយក្រុមហ៊ុន ដើម្បីដោះស្រាយភាពចម្រូងចម្រាស់ដែលនៅសល់ឲ្យរហ័សចប់ កុំឲ្យមានបញ្ហាអសកម្មមិនសមស្របនេះតទៅទៀត ព្រោះភាគីទាំងពីរជាដៃគូអភិវឌ្ឍន៍ និងជាអ្នកភូមិផងរបងជាមួយគ្នា។ តាមការពិនិត្យជាក់ស្តែងមក ខាងក្រុមហ៊ុនមិនទាន់បានរំលោភលើដីរបស់ប្រជាពលរដ្ឋនៅឡើយ។ ដោយឡែកអ្នកដែលតែងតែធ្វើការញុះញង់ប្រជាពលរដ្ឋឲ្យតវ៉ាទាមទារដី និងបង្កើតបញ្ហាអសកម្មមិនសមស្របផ្សេងៗ ត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួនតទៅទៀតទៅ ហើយប្រសិនបើមិនព្រមទទួលយកការសម្របសម្រួល និងភាពយោគយល់នេះ ពោលគឺប្រសិនបើការទាមទារដី និងបញ្ហាអសកម្មមិនសមស្របផ្សេងៗទៀតនៅតែកើតមាននោះ អាជ្ញាធរនឹងប្រគល់នាទីនេះជូនថ្នាក់ដឹកនាំខាងលើដើម្បីអនុវត្តតាមនីតិវិធីច្បាប់។ លោកអភិបាលរងស្រុក ក៏បានស្នើដល់លោកមេភូមិ និងអនុភូមិទាំងអស់ឲ្យជួយផ្សព្វផ្សាយអំពីខ្លឹមសារ និងស្មារតីនៃអង្គប្រជុំថ្ងៃនេះដល់ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនឲ្យបានជ្រួតជ្រាបផង។

ការពិភាក្សាពិគ្រោះយោបល់នេះបានបញ្ចប់នៅវេលាម៉ោងដប់មួយ និងហាសិបប្រាំនាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់។

### ៦.២.២.៣ ការពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធទៅនឹងដីសម្បទានសេដ្ឋកិច្ចនៅឃុំកន្ទួត

កាលពីថ្ងៃទីប្រាំមួយ ខែតុលា ឆ្នាំពីរពាន់ដប់បួន វេលាម៉ោងដប់បួនរសៀល នៅសាលាឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ មានរៀបចំការពិភាក្សាពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហ្វឿក ជាមួយប្រជាពលរដ្ឋក្នុងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ។ ការពិគ្រោះយោបល់នេះ មានការចូលរួមពីលោកនាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ លោកមេឃុំកន្ទួត ជំទប់ទី១ ជំទប់ទី២ តំណាងក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហ្វឿក ចំនួនពីរនាក់ បុគ្គលិកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ចំនួនមួយនាក់ មេភូមិ អនុភូមិអាលច មេក្រុម និងអនុក្រុមភូមិឧបសម្ព័ន្ធស្រែននសរុបទាំងអស់ចំនួន ១៧នាក់ (ឧបសម្ព័ន្ធ៦-១ តារាង២, ឧបសម្ព័ន្ធ៦-២ រូបភាព)។ អ្នកចូលរួមមាន៖

**តារាង ៦-៤៖** សមាសភាពចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន-ប៊ិញហ្វឿក (អេស ប៊ី ខេ) ជាមួយប្រជាពលរដ្ឋក្នុងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ

| លរ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន |
|---|---|---|---|---|
| ១ | ម៉ៅ សុខជា | ប្រ | អនុប្រធានមន្ទីរ | មន្ទីរអភិវឌ្ឍន៍ជនបទ |

Draft

| | | | | |
|---|---|---|---|---|
| ២ | សឹង ផល | ប្រ | មេឃុំ | ឃុំកន្ទួត |
| ៣ | ណៃ សោភ័ណ | ប្រ | ជំទប់ទី១ | ឃុំកន្ទួត |
| ៤ | ហួត គុយហេង | ប្រ | ជំទប់ទី២ | ឃុំកន្ទួត |
| ៥ | យុន សារ៉ាន់នី | ប្រ | មេភូមិ | ភូមិៈរាលច |
| ៦ | ជុំ សាមី | ស្រ | អនុភូមិ | ភូមិអាលច |
| ៧ | ស្រ៊ូ រាក់ | ប្រ | មេក្រុម | ភូមិអាលច |
| ៨ | ថេង ទ្រី | ប្រ | អនុក្រុម | ភូមិអាលច |
| ៩ | បណ្ឌិត លី សុពណ៌-មុនី | ប្រ | នាយក | ក្រុមហ៊ុន ETS |
| ១០ | សយ សុខដុម | ប្រ | បុគ្គលិក | ក្រុមហ៊ុន ETS |
| ១១ | កែវ សុវណ្ណ | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ១២ | ហ៊ិន វិសេស | ប្រ | ប្រធានផ្នែកធនធានមនុស្ស | ក្រុមហ៊ុន DTSG-BP |

បន្ទាប់ពីផ្ដើមបើកការពិភាក្សាពិគ្រោះយោបល់រួចមក **លោកបណ្ឌិត លី សុពណ៌-មុនី** បានមានមតិថា៖ ដោយសារថ្ងៃនេះលោកមានការងារមកពិភាក្សាពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងភូមិពាក់ព័ន្ធជុំវិញដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក ស្ដីពីការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់លើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្ដល់នូវជំរើសនៃការរកចំណូលគ្រួសារ និងចង់បានទិន្នន័យចុងក្រោយពាក់ព័ន្ធនឹងបញ្ហាវាំងស្ទះ ឬចម្រូងចម្រាស់ផ្សេងៗ ដែលនៅសល់មិនទាន់ដោះស្រាយរួច រវាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក ជាមួយនឹងប្រជាពលរដ្ឋក្នុងភូមិអាលច និងភូមិឧបសម្ព័ន្ធស្រែនន ដើម្បីរៀបចំដាក់ក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថានពេញលេញផង ជួនជាថ្ងៃនេះមានឱកាសល្អដែលមានគ្រប់ភាគីមកចូលរួមរួមទាំងតំណាងក្រុមហ៊ុនទៀតផងនោះ ទើបលោកសូមឲ្យជួយរៀបចំការប្រជុំនេះឡើង។ យោងតាមការសិក្សារបស់ក្រុមការងារ អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស បានឲ្យដឹងថា៖ នៅក្នុងភូមិអាលច ពិសេសនៅភូមិឧបសម្ព័ន្ធស្រែនន មានសំណើមួយចំនួនដូចជា៖ ការស្នើសុំពង្រីកផ្លូវចូលទីទួលសុវត្ថិភាពឲ្យបានទទឹង ៣០ម៉ែត្រ ការស្នើសុំទុកដីទ្រនាប់ជងអូរឲ្យបានចម្ងាយ ២០០ម៉ែត្រពីចំណុចកណ្ដាលនៃអូរ ការស្នើសុំធ្វើផ្លូវរវាងទំនប់ព្រំដីប្រវែង ១០០ម៉ែត្រ។ល។

លោក **កែវ សុវណ្ណ** តំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក បានមានមតិឆ្លើយថា៖ ការវាស់វែងដីរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដីក្រុមហ៊ុនបានបញ្ចប់ហើយ គឺមាន ២៣៣ក្បាលដី ស្មើនឹង ៤៦៨,២៣ហ.ត។ ចំពោះផ្លូវចូលទីទួលសុវត្ថិភាព ភាគីទាំងសងខាងបានឯកភាពលើទំហំទទឹង ២៨ម៉ែត្រហើយ។ ឯសំណើសុំផ្លូវរវាងព្រំដីប្រវែង ១០០ម៉ែត្រវិញ ក្រុមហ៊ុនក៏បានឯកភាពហើយដែរ។ ចំពោះការសន្យារបស់ក្រុមហ៊ុនមានការយឺតយ៉ាវមិនទាន់បានបំពេញ គឺដោយសារក្រុមហ៊ុនមានការមមាញឹកក្នុងការដាំកៅស៊ូឲ្យបានទាន់ពេលវេលានៅរដូវវស្សា។ ការអនុវត្តន៍នូវសន្យាទាំងនោះ ក្រុមហ៊ុននឹងបំពេញនៅរដូវក្ដៅ។

លោក ស្រ៊ូ រាក់ មេក្រុមភូមិឧបសម្ព័ន្ធស្រែនន បានមានមតិបញ្ជាក់ថា៖ រាល់បញ្ហាដែលកើតមានភាគីទាំងពីរបានជួបសម្របសម្រួលគ្នាដោះស្រាយរួចរាល់ហើយ នៅសល់តែការអនុវត្តន៍នូវកិច្ចសន្យារបស់

ក្រុមហ៊ុនប៉ុណ្ណោះ។ ប្រជាពលរដ្ឋកំពុងរង់ចាំការសន្យាទាំងនេះ ហើយតាមការបំភ្លឺរបស់តំណាងក្រុមហ៊ុនខាងលើ ពួកគាត់សង្ឃឹមថា ភាគីក្រុមហ៊ុននឹងបំពេញការសន្យារបស់ខ្លួននាពេលឆាប់ៗខាងមុខនេះ។

បន្ទាប់មកលោកបណ្ឌិត **លី សុពណ៌-មុនី** បានមានប្រសាសន៍ថា៖ លោកមានសេចក្តីរីករាយណាស់នៅពេលដែលដឹងថា ប្រជាពលរដ្ឋមានចេតនាចូលរួមដោះស្រាយរាល់បញ្ហាចម្រូងចម្រាស់ដែលនៅសេសសល់ និងស្នើបន្តឲ្យសហការគ្នាតទៅទៀតដើម្បីបញ្ចប់បញ្ហាទាំងអស់នោះជាស្ថាពរ។

ការពិភាក្សាគ្នានេះប្រព្រឹត្តទៅអស់រយៈពេលមួយម៉ោងនិងសាមសិបនាទី ហើយបានបញ្ចប់នៅម៉ោងដប់ប្រាំ និងសាមសិបនាទីរសៀលនៃថ្ងៃខែ និងឆ្នាំដដែល ប្រកបដោយភាពយោគយល់គ្នាទៅវិញទៅមក ។

## ៦.២.២.៤ ការពិគ្រោះយោបល់លើការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកចំណូលគ្រួសាររបស់ប្រជាពលរដ្ឋនៅឃុំថ្មី

Draft

កាលពីថ្ងៃទីប្រាំមួយ ខែតុលា ឆ្នាំពីរពាន់ដប់បួន វេលាម៉ោងប្រាំបួនព្រឹក នៅសាលាឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ មានរៀបចំការពិគ្រោះយោបល់លើការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។ ការពិគ្រោះយោបល់នេះ មានការចូលរួមពីលោកអភិបាលរងស្រុកចិត្របុរី លោកអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ លោកមេឃុំថ្មី ជំទប់ទី១ ជំទប់ទី២ មេភូមិ អនុភូមិឃ្មៀរ ភូមិស្វាយជ្រុំ ភូមិថ្មី ភូមិត្នោត និងភូមិឧបសម្ព័ន្ធយៃ ប្រជាពលរដ្ឋដែលមានបទពិសោធន៍លើការងារកសិកម្មចំនួនបីនាក់ក្នុងមួយភូមិ នាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស តំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្សៀក ព្រមទាំងបុគ្គលិកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស សរុបចំនួន ៣៥នាក់ (ឧបសម្ព័ន្ធ៦-១ តារាង៣, ឧបសម្ព័ន្ធ៦-២ រូបភាព)។ សមាសភាពចូលរួមមាន៖

**តារាង៦-៥៖ សមាសភាពចូលរួមក្នុងការពិគ្រោះយោបល់លើការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ**

| លរ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន |
|---|---|---|---|---|
| ១ | អ៊ួង សម្បត្តិ | ប្រ | អភិបាលរង | ស្រុកចិត្របុរី |
| ២ | មុំ ខាំ | ប្រ | មេឃុំ | ឃុំថ្មី |
| ៣ | យឹម ម៉ៅ | ប្រ | ជំទប់ទី១ | ឃុំថ្មី |
| ៤ | ម៉ឹង ស្រេន | ប្រ | ជំទប់ទី២ | ឃុំថ្មី |
| ៥ | គាំ គឿន | ប្រ | ស្មៀន | ឃុំថ្មី |
| ៦ | សេន អឿន | ប្រ | មេភូមិ | ភូមិថ្មី |
| ៧ | ហ៊ិង វាសនា | ស្រ | មេភូមិ | ភូមិត្នោត |

| | | | | |
|---|---|---|---|---|
| ៨ | អ៊ិត ញ៉ុញ | ប្រ | មេភូមិ | ភូមិប្លៀរ |
| ៩ | តាំង ពោន | ប្រ | មេភូមិ | ភូមិស្វាយជ្រុំ |
| ១០ | វ៉ាន់ ក្រូច | ប្រ | អនុភូមិ | ភូមិប្លៀរ |
| ១១ | ហ៊ី ពៅ | ប្រ | ជំនួយការ | ភូមិស្វាយជ្រុំ |
| ១២ | យិន វឿន | ស្រ | ប្រជាជន | ភូមិត្នោត |
| ១៣ | បាក់ ឆត | ប្រ | ប្រជាជន | ភូមិត្នោត |
| ១៤ | សឿង ខុន | ប្រ | ប្រជាជន | ភូមិត្នោត |
| ១៥ | ថាប់ វ៉ា | ប្រ | ប្រជាជន | ភូមិប្លៀរ |
| ១៦ | ស៊ិន ញឹក | ប្រ | ប្រជាជន | ភូមិថ្មី |
| ១៧ | ខាំ ម៉ុង | ប្រ | ជំនួយការស្មៀន | ភូមិថ្មី |
| ១៨ | ជាម វុទ្ធី | ប្រ | សមាជិក | ភូមិថ្មី |
| ១៩ | បេត ម៉េត | ប្រ | ប្រធានសហគមន៍ព្រៃឈើ | ភូមិថ្មី |
| ២០ | សូ គឿន | ប្រ | ប្រជាជន | ភូមិថ្មី |
| ២១ | ផៃ កែ | ប្រ | ប្រជាជន | ភូមិប្លៀរ |
| ២២ | ប្រាយ ទិត្យ | ប្រ | ប្រជាជន | ភូមិស្វាយជ្រុំ |
| ២៣ | តុត យន | ប្រ | ប្រជាជន | ភូមិស្វាយជ្រុំ |
| ២៤ | ហ៊ុន វិសេស | ប្រ | ប្រធានសហគមន៍ | ក្រុមហ៊ុន DTSG-BP |
| ២៥ | អ៊ឹម សុធី | ប្រ | តំណាងក្រុមហ៊ុន | ក្រុមហ៊ុន DTSG-BP |
| ២៦ | ជៀង តេង | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ២៧ | កែវ សុវណ្ណ | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ២៨ | ផាន់ វណ្ណៈ | ប្រ | ជំនួយការ | ក្រុមហ៊ុន DTSG-BP |
| ២៩ | នៀល ពៅ | ប្រ | ប្រជាជន | ភូមិស្វាយជ្រុំ |
| ៣០ | ផុន សាន | ប្រ | ប្រជាជន | ភូមិប្លៀរ |
| ៣១ | ហង ចំរើន | ប្រ | PC | KBSC |
| ៣២ | ជួន សំអាត | ស្រ | PO | CED |
| ៣៣ | ម៉ៅ សុខជា | ប្រ | អនុប្រធានមន្ទីរ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ៣៤ | បណ្ឌិត លី សុពណ៌-មុនី | ប្រ | នាយក | ក្រុមហ៊ុន ETS |
| ៣៥ | សយ សុខដុម | ប្រ | បុគ្គលិក | ក្រុមហ៊ុន ETS |

បន្ទាប់ពីលោក **មុំ ខាំ** មេឃុំថ្មីមានប្រសាសន៍ចាប់ផ្តើមបើកការប្រជុំពិគ្រោះយោបល់រួចមក **បណ្ឌិត លី សុពណ៌-មុនី** នាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស បានមានមតិលើកឡើងអំពីភាពចាំបាច់នៃជំរើសមុខរបរចិញ្ចឹមជីវិតដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ ក្នុងការលើកស្ទួយកំរិតជីវភាពគ្រួសាររបស់ប្រជាពលរដ្ឋក្នុងតំបន់ក្បែរទីតាំងដីសម្បទានសេដ្ឋកិច្ចនៃគំរោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន ដូទិសាយហ្គន-ប៊ិញហឿក។ ក្នុងន័យនេះ លោកបណ្ឌិតបានបង្ហាញពីទំលាប់ចាស់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលតែងតែ

ប្រកបរបរចិញ្ចឹមជីវិតដោយសារការធ្វើស្រែសំរាប់ទុកហូប និងលក់ពលកម្ម ឬរកេកធនធានធម្មជាតិ ពិសេសផលអនុផលព្រៃឈើ ហើយដែលធនធានធម្មជាតិទាំងនោះបាននឹងកំពុងបន្តការបាត់បង់ទៅៗ ចំណែកជីវភាពរបស់ប្រជាពលរដ្ឋក៏កាន់តែក្រីក្រឡើងៗ។ លោកបានបន្តទៀតថា ដោយសារមើលឃើញនូវការធ្លាក់ចុះនៃកំរិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ លោកមានបំណងនឹងរៀបចំផែនការអភិវឌ្ឍន៍ក្នុងភូមិដែលពាក់ព័ន្ធដូចជា ភូមិឬៀរ ភូមិថ្មី ភូមិស្វាយជ្រុំ ភូមិក្រសាំង ភូមិត្នោត និងភូមិឧបសម្ព័ន្ធយ៉ៃ។

**លោក វ៉ាន់ ក្រូច** ជាអនុភូមិឬៀរបានសួរថា៖ តើប្រជាពលរដ្ឋអាចទទួលបានអ្វី ឬផែនការអភិវឌ្ឍន៍សហគមន៍នេះនឹងជួយអ្វីខ្លះដល់ពួកគាត់?

**បណ្ឌិត លី សុពណ៌-មុនី** បានឆ្លើយតបដោយធ្វើការប្រៀបធៀបរវាងទិន្នផល និងប្រាក់ចំណូលបានមកពីការធ្វើស្រែ ចម្ការដំណាំបន្ទាប់បន្សំផ្សេងៗ ទៅនឹងទិន្នផលនិងប្រាក់ចំណូលដែលបានមកពីការដាំដំណាំស្វាយចន្ទីក្នុងមួយហិកតា។ តាមការវិភាគសេដ្ឋកិច្ចបង្ហាញឲ្យឃើញថា ប្រាក់ចំណូលបានមកពីដាំដំណាំស្វាយចន្ទី មានកំរិតខ្ពស់ជាងប្រាក់ចំណូលបានមកពីដំណាំស្រូវ។ ម៉្យាងទៀតដំណាំបន្ទាប់បន្សំផ្សេងៗដូចជា ដំឡូងដែលជាប្រភេទដំណាំមួយមានហានីភ័យខ្ពស់ក្នុងតំបន់នេះ ព្រោះមានទឹកជំនន់ជារៀងរាល់ឆ្នាំ។ ប្រជាពលរដ្ឋត្រូវព្យាយាមរៀនសូត្រនូវចំណេះដឹងអំពីបច្ចេកទេសថ្មីផ្សេងៗ និងបទពិសោធន៍ល្អៗដែលអាចយកមកអនុវត្តឲ្យចេញជាផ្លែផ្កា ដោយការកែប្រែទំលាប់ចាស់ដែលគ្មានទំនោរទៅរកការវិវឌ្ឍន៍រីកចំរើន ដើម្បីរំដោះខ្លួនចេញពីភាពក្រីក្រដោយឈរលើការអភិវឌ្ឍន៍ខ្លួនឯង។ ក្រុមការងារ ETS កំពុងត្រៀមរៀបចំធ្វើផែនការអភិវឌ្ឍន៍ក្នុងភូមិគោលដៅ ដោយប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ដែលមាននៅក្នុងផែនការប្រើប្រាស់ថវិកាប្រចាំឆ្នាំនីមួយៗរបស់ក្រុមហ៊ុន ដូទីសាយហ្គន-បិញហ្សៀក ក្នុងរយៈកាលនៃកិច្ចសន្យាវិនិយោគអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មកៅស៊ូ ក្នុងព្រះរាជាណាចក្រកម្ពុជា។ លោកបណ្ឌិតបានស្នើដល់ក្រុមប្រឹក្សាឃុំ សហការគ្នាក្នុងការប្រមូលព័ត៌មានអំពីប្រជាពលរដ្ឋដែលមានបំណងចង់បង្កើនកំរិតជីវភាពគ្រួសាររបស់ខ្លួន តាមរយៈការអភិវឌ្ឍន៍វិស័យកសិកម្មលើដីស្រែចម្ការដែលពួកគាត់មាន។

បន្ទាប់ពី **បណ្ឌិត លី សុពណ៌-មុនី** មានមតិរួចមក **លោក មុំ - ខាំ** មេឃុំថ្មីបានមានប្រសាសន៍ថា៖ លោកមានសេចក្តីរីករាយណាស់ចំពោះគោលបំណងនេះ ដោយឡែកនៅមានបញ្ហាជីផ្លីសេសសល់មួយចំនួនរវាងប្រជាពលរដ្ឋក្នុងភូមិពាក់ព័ន្ធនានា ជាមួយនឹងក្រុមហ៊ុន ដូទីសាយហ្គន-បិញហ្សៀកនេះ។

**លោក អ៊ឹម សុធី** តំណាងឲ្យក្រុមហ៊ុន ដូទីសាយហ្គន-បិញហ្សៀក បានមានប្រសាសន៍ថា៖ ក្រុមហ៊ុនដូទីសាយហ្គន-បិញហ្សៀក បច្ចុប្បន្នជាក្រុមហ៊ុនវិនិយោគអាមេរិក ដែលបានផ្ទេរបន្តពីក្រុមហ៊ុន ដូទីសាយហ្គន-បិញហ្សៀក ដូច្នេះមិនមែនជាក្រុមហ៊ុនវៀតណាមទៀតទេ គ្រាន់តែទុកឈ្មោះនៅដដែលប៉ុណ្ណោះ។ លោកបានលើកអំពីផលប្រយោជន៍នៃការវិនិយោគ ក្នុងនោះមាន៖ អាទិភាពការងារសំរាប់ប្រជាពលរដ្ឋនៅក្នុងក្រុមហ៊ុន ការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា ផ្លូវលំ ប៉ុស្តិ៍សុខភាពប្រចាំក្រុមហ៊ុន និងការបង់ពន្ធចូលរដ្ឋជាដើម។ លោកបានសំណូមពរឲ្យប្រជាពលរដ្ឋមានការយោគយល់ និងចូលរួមធ្វើសម្បទានទៅវិញទៅមក ដើម្បីការអភិវឌ្ឍន៍ក្នុងតំបន់នេះឲ្យបានជោគជ័យ។ ក្រុមហ៊ុនបាននិងកំពុងធ្វើសម្បទានយ៉ាងច្រើនដល់ប្រជាពលរដ្ឋ ហើយការយឺតយ៉ាវនៃការអនុវត្តន៍សន្យារបស់ក្រុមហ៊ុនដែលមិនទាន់បានបំពេញ គឺ

ដោយសារក្រុមហ៊ុនមានការមមាញឹកក្នុងការដាំដុះឲ្យបានទាន់ពេលវេលា។ ក្រុមហ៊ុនសន្យានឹងធ្វើតាមការសន្យានៅរដូវក្តៅនេះ។

**បណ្ឌិត លី សុពណ៌-មុនី** បានមានមតិបន្ថែមក្នុងន័យសម្របសម្រួលទំនាក់ទំនងរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុនថា៖ ភាគីទាំងពីរគួរសម្របសម្រួលគ្នាឲ្យបានឆាប់រហ័ស និងមានចេតនាសម្បទានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យគំរោងវិនិយោគនេះមានដំណើរការទៅយ៉ាងរលូន ហើយប្រជាពលរដ្ឋនឹងអាចទទួលបាននូវផលវិជ្ជមានសមស្របមួយ ក្នុងការជំរុញការអភិវឌ្ឍន៍សហគមន៍ឲ្យបានលឿនទៅមុខផងដែរ។ យោងតាមការចុះអង្កេតសិក្សាសេដ្ឋកិច្ច-សង្គមរបស់ក្រុមការងារក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឹវីស ចាប់ពីថ្ងៃទី ១៧ ដល់ ២៧ ខែ សីហា ឆ្នាំ ២០១៤ ថ្មីៗនេះ បានឲ្យដឹងថា ប្រជាពលរដ្ឋក្នុងភូមិពាក់ព័ន្ធទាំងអស់មានសំណូមពរចង់បានផ្លូវលំ អណ្តូងទឹក សាលារៀន គ្រូបង្រៀន និងប៉ុស្តិ៍សុខភាព។ ចំពោះសំណើទាំងនេះអាចទទួលបានដំណោះស្រាយពីប្រភពផ្សេងទៀត ពោលគឺ ប្រជាពលរដ្ឋអាចធ្វើសំណើទៅមន្ទីរអភិវឌ្ឍន៍ជនបទតាមរយៈអាជ្ញាធរភូមិ ឃុំ និងស្រុក។ ដោយឡែក ការបន្ថែមថ្នាក់រៀន និងគ្រូបង្រៀន ត្រូវធ្វើសំណើទៅមន្ទីរអប់រំ ហើយប៉ុស្តិ៍សុខភាពត្រូវធ្វើសំណើទៅមន្ទីរសុខាភិបាលខេត្ត។

**លោក ម៉ៅ សុខជា** អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទបានមានប្រសាសន៍បញ្ជាក់ថា សំណូមពរសុំផ្លូវលំ និងអណ្តូងទឹករបស់ប្រជាពលរដ្ឋក្នុងភូមិពាក់ព័ន្ធនីមួយៗ ត្រូវរៀបចំជាសំណើទៅមន្ទីរអភិវឌ្ឍន៍ជនបទតាមរយៈអាជ្ញាធរភូមិ ឃុំ ស្រុក ដើម្បីផ្តល់លទ្ធភាពឲ្យមន្ទីរលើកទិសដៅរៀបចំផែនការប្រចាំឆ្នាំ។

បន្ទាប់មកលោក **អ៊ួង សម្បត្តិ** អភិបាលរងស្រុកចិត្របុរី បានមានមតិបន្ថែមថា៖ លោកមេភូមិ និងអនុភូមិទាំងអស់ ត្រូវពាំនាំខ្លឹមសារ និងស្មារតីនៃការប្រជុំថ្ងៃនេះ ទៅជំរាបបងប្អូនប្រជាពលរដ្ឋនៅតាមភូមិនីមួយៗ បានយល់គ្រប់ៗគ្នាអំពីគោលបំណងនៃការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍នេះ។ ប្រជាពលរដ្ឋត្រូវតែធ្វើការកែប្រែទំលាប់ចាស់ដែលគ្មានការរីកចំរើន ឈោងចាប់យកចំណេះដឹង និងបទពិសោធន៍ថ្មីមកអភិវឌ្ឍន៍ខ្លួនឯង ស្របពេលជាមួយនឹងឱកាសដែលមានការជ្រោមជ្រែងពីមជ្ឈដ្ឋានខាងក្រៅ។

បន្ទាប់ពីមានការពន្យល់បង្ហាញពីគោលបំណង និងសារៈប្រយោជន៍នៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍សំរាប់អនុវត្តកម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសាររួចមក តាមការពិនិត្យសង្កេតជាក់ស្តែងលើទិដ្ឋភាពទូទៅក្នុងអង្គពិភាក្សាពិគ្រោះយោបល់បានបង្ហាញថា ប្រជាពលរដ្ឋដែលបានចូលរួមមិនសូវយកចិត្តទុកដាក់ និងចាប់អារម្មណ៍ចំពោះផែនការនេះទេ នេះអាចមកពីពួកគាត់ភាគច្រើនជាជនជាតិភាគតិច ធ្លាប់តែរស់នៅពឹងផ្អែកលើកត្តាធម្មជាតិទាំងស្រុង ហើយពួកគាត់ចាប់អារម្មណ៍តែទៅលើអ្វីដែលមានស្រាប់ក្នុងមជ្ឈដ្ឋានធម្មជាតិ។ ម្យ៉ាងទៀត ដោយពួកគាត់ខ្លះមានដីស្រែចម្ការតិចតួច និងខ្លះទៀតពុំមានដីស្រែ ឬចម្ការទាល់តែសោះ ហេតុនេះពួកគាត់មិនចាប់អារម្មណ៍នឹងសារៈប្រយោជន៍ នៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់អនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសារដូចជាការផ្លាស់ប្តូរការធ្វើស្រែតាមរដូវកាល ទៅជាដំណាំស្វាយចន្ទីដែលផ្តល់ផលរយៈពេលវែងនោះទេ។ ចំពោះមុខ ពួកគាត់ចង់បានតែផ្លូវលំ អណ្តូងទឹកស្អាត សាលារៀន និងប៉ុស្តិ៍សុខភាពប៉ុណ្ណោះ។ ហេតុដូចនេះ លោកបណ្ឌិត លី សុពណ៌-មុនី បានផ្តល់មតិទៀតថា ដោយសារមើលឃើញនូវការធ្លាក់ចុះនៃកំរិតជីវភាព

Draft

របស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ទើបលោកមានបំណងនឹងរៀបចំផែនការអភិវឌ្ឍន៍ក្នុងភូមិពាក់ព័ន្ធ ក្នុងនោះ ភូមិឧបសម្ព័ន្ធយ៉ៃដែលជាភូមិមួយនៅដាច់ស្រយាលពីទីប្រជុំជន ប្រជាពលរដ្ឋមានកំរិតជីវភាពទាប ហើយ ប្រជាពលរដ្ឋក្នុងភូមិនេះទៀតសោតក៏ងាយទទួលរងនូវគ្រោះធម្មជាតិ ដូចជាគ្រោះទឹកជំនន់ជាដើម។ យោង តាមលទ្ធផលនៃការធ្វើអង្កេតរបស់ក្រុមការងារ ETS ពីថ្ងៃទី ១៧ ដល់ ២៧ ខែ សីហា ឆ្នាំ ២០១៤ កន្លង មកនេះ ក្រុមការងារបានសម្រេចរៀបចំធ្វើផែនការអភិវឌ្ឍន៍ក្នុងភូមិឧបសម្ព័ន្ធយ៉ៃ ដោយប្រើប្រាស់មូលនិធិ អភិវឌ្ឍន៍សហគមន៍ ដែលមាននៅក្នុងផែនការប្រើប្រាស់ថវិកាប្រចាំឆ្នាំនីមួយៗរបស់ក្រុមហ៊ុន ដូទីសាយ ហ្គន-ប៊ិញហ្មឿក ក្នុងរយៈកាលនៃកិច្ចសន្យាវិនិយោគអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មកៅស៊ូក្នុងព្រះរាជា ណាចក្រកម្ពុជា។ លោកបណ្ឌិតបានស្នើដល់មេភូមិ និងអនុភូមិត្នោត ពិសេសលោកស្រីមេភូមិឧបសម្ព័ន្ធយ៉ៃ ឲ្យជួយផ្សព្វផ្សាយនូវផែនការនេះ ហើយប្រមូលព័ត៌មានអំពីប្រជាពលរដ្ឋ ដែលមានបំណងចង់បង្កើនកំរិត ជីវភាពគ្រួសារទៅតាមផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ តាមរយៈនៃការផ្លាស់ប្តូរមុខរបររកចំណូល គ្រួសារពីការធ្វើស្រែចម្ការដែលពួកគាត់មាន ទៅជាការដាំដំណាំស្វាយចន្ទីដែលអាចទទួលផលរយៈពេលវែង និងមានចំណូលច្រើនជាងវិញ។

**លោកបណ្ឌិត លី សុពណ៌-មុនី** មានមតិប្រកបដោយភាពសុទិដ្ឋិនិយមថា ការរៀបចំផែនការមូលនិធិ អភិវឌ្ឍន៍សហគមន៍នេះ នឹងទទួលបានជោគជ័យ ហើយនឹងក្លាយទៅជាផែនការអភិវឌ្ឍន៍សហគមន៍គំរូ មួយនៅទូទាំងប្រទេស ក្នុងនោះ ដំណាំស្វាយចន្ទីជាជំរើសសមស្របជាងគេក្នុងយុទ្ធសាស្ត្រលើកស្ទួយកំរិត ជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ជុំវិញដីសម្បទានសេដ្ឋកិច្ចវិនិយោគអភិវឌ្ឍន៍លើដំណាំកសិ-ឧស្សាហកម្ម កៅស៊ូរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្មឿក ក្នុងទឹកដីស្រុកចិត្របុរី ខេត្តក្រចេះ។

កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់នេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់មួយ និងហាសិបប្រាំនាទី ថ្ងៃត្រង់នៃថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយោគយល់គ្នាទៅវិញទៅមក។

### ៦.២.២.៥ ការពិគ្រោះយោបល់លើការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជម្រើសនៃការរកចំណូលគ្រួសាររបស់ប្រជាពលរដ្ឋនៅឃុំកន្ទួត

នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ២០១៤ វេលាម៉ោងដប់បួនរសៀល នៅសាលាឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ មានរៀបចំការពិគ្រោះយោបល់លើការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ សំរាប់ការ អនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូល គ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ។ ការពិគ្រោះយោបល់នេះ មានការចូលរួម ពីអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ លោកមេឃុំកន្ទួត ជំទប់ទី១ ជំទប់ទី២ មេភូមិ អនុភូមិអាលច មេក្រុម និងអនុក្រុមនៃភូមិឧបសម្ព័ន្ធស្រែនន នាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស តំណាងក្រុមហ៊ុន ដូទី សាយហ្គន-ប៊ិញហ្មឿក ព្រមទាំងបុគ្គលិកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក ស៊ីវីស សរុបចំនួន ១២នាក់ (ឧបសម្ព័ន្ធ៦-១ តារាង២)។ សមាសភាពចូលរួមមាន៖

Draft

តារាង៦-៦៖ សមាសភាពចូលរួមក្នុងការពិគ្រោះយោបល់លើការរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍សំរាប់ការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ

| លរ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន |
|---|---|---|---|---|
| ១ | ម៉ៅ សុខជា | ប្រ | អនុប្រធានមន្ទីរ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ២ | សឹង ផល | ប្រ | មេឃុំ | ឃុំកន្ទួត |
| ៣ | ណៃ សោភ័ណ | ប្រ | ជំទប់ទី១ | ឃុំកន្ទួត |
| ៤ | ហួត គុយហេង | ប្រ | ជំទប់ទី២ | ឃុំកន្ទួត |
| ៥ | យុន សារ៉ាន់នី | ប្រ | មេភូមិ | ភូមិអាលច |
| ៦ | ជុំ សាមី | ស្រ | អនុភូមិ | ភូមិអាលច |
| ៧ | ស្រ៊ុំ រាក់ | ប្រ | មេក្រុម (ស្រែនន) | ភូមិអាលច |
| ៨ | ថេង ទ្រី | ប្រ | អនុក្រុម (ស្រែនន) | ភូមិអាលច |
| ៩ | បណ្ឌិត លី សុពណ៌-មុនី | ប្រ | នាយក | ក្រុមហ៊ុន ETS |
| ១០ | សយ សុខដុម | ប្រ | បុគ្គលិក | ក្រុមហ៊ុន ETS |
| ១១ | កែវ សុវណ្ណ | ប្រ | បុគ្គលិក | ក្រុមហ៊ុន DTSG-BP |
| ១២ | ហ៊ិន វិសេស | ប្រ | ប្រធានផ្នែកធនធានមនុស្ស | ក្រុមហ៊ុន DTSG-BP |

**លោកបណ្ឌិត លី សុពណ៌-មុនី** នាយកក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឹវីស បានមានមតិចាប់ផ្តើមកិច្ចពិភាក្សាពិគ្រោះយោបល់ ដោយបានលើកឡើងអំពីភាពចាំបាច់នៃជំរើសមុខរបរចិញ្ចឹមជីវិតដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ ក្នុងការលើកស្ទួយកំរិតជីវភាពគ្រួសាររបស់ប្រជាពលរដ្ឋក្នុងតំបន់ក្បែរទីតាំងដីសម្បទានសេដ្ឋកិច្ចនៃគំរោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក។ លោកបណ្ឌិតបានបង្ហាញពីទំលាប់ចាស់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ដែលតែងប្រកបរបរចិញ្ចឹមជីវិតដោយសារការធ្វើស្រែចម្ការសំរាប់ទុកហូប និងលក់ពលកម្ម ឬរករកធនធានធម្មជាតិ ពិសេសផលអនុផលព្រៃឈើ ដើម្បីរកប្រាក់ចំណូលសំរាប់ទ្រទ្រង់ជីវភាពគ្រួសារប្រចាំថ្ងៃ ហើយដែលធនធានធម្មជាតិទាំងនោះបាននិងកំពុងបន្តបាត់បង់ទៅៗ ចំណែកជីវភាពរបស់ប្រជាពលរដ្ឋក៏កាន់តែក្រីក្រឡើងៗ។ លោកបណ្ឌិតបានបន្តទៀតថា ដោយសារមើលឃើញនូវការធ្លាក់ចុះនៃកំរិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ លោកមានបំណងនឹងរៀបចំផែនការអភិវឌ្ឍន៍ក្នុងភូមិពាក់ព័ន្ធ គឺភូមិឧបសម្ព័ន្ធស្រែននរបស់ភូមិអាលច ដែលជាភូមិមួយធ្លាប់នៅដាច់ស្រយាលពីទីប្រជុំជន ហើយបច្ចុប្បន្នស្ថិតនៅជាប់នឹងព្រំដីសម្បទានសេដ្ឋកិច្ច ដូទីសាយហ្គន-ប៊ិញហ្វឿក ជាពិសេស ប្រជាពលរដ្ឋក្នុងភូមិនេះមានកំរិតជីវភាពទាប ងាយទទួលរងពីគ្រោះធម្មជាតិដូចជា គ្រោះទឹកជំនន់ជាដើម។ តាមរយៈការធ្វើអង្កេតរបស់ក្រុមការងារ ETS ពីថ្ងៃទី ១៧ ដល់ ២៧ ខែ សីហា ឆ្នាំ ២០១៤ នេះ ក្រុមការងារ ETS សំរេចរៀបចំធ្វើផែនការអភិវឌ្ឍន៍ក្នុងភូមិស្រែនន ដោយប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍ដែលមាននៅក្នុងផែនការប្រើប្រាស់ថវិកាប្រចាំឆ្នាំនីមួយៗរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក ក្នុងកំឡុងពេលនៃកិច្ចសន្យាវិនិយោគអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មកៅស៊ូក្នុងព្រះរាជាណាចក្រ

Draft

កម្ពុជា។ លោកបណ្ឌិតបានស្នើដល់មេក្រុម និងអនុក្រុមនៃភូមិឧបសម្ព័ន្ធស្រែនន ឲ្យជួយផ្សព្វផ្សាយនូវផែនការនេះ ហើយប្រមូលព័ត៌មានអំពីប្រជាពលរដ្ឋ ដែលមានបំណងចង់បង្កើនកំរិតជីវភាពគ្រួសារទៅតាមផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ តាមរយៈនៃការផ្លាស់ប្តូរមុខរបររកចំណូលគ្រួសារពីការដីស្រែចម្ការដែលពួកគាត់មាន ទៅជាការដាំដំណាំស្វាយចន្ទីដែលអាចទទួលផលរយៈពេលវែង និងមានចំណូលច្រើនជាងវិញ។ លោកបណ្ឌិតក៏បានធ្វើការប្រៀបធៀបជូនប្រជាពលរដ្ឋឲ្យកាន់តែយល់ច្បាស់រវាងប្រាក់ចំណូលបានមកពីការធ្វើស្រែ និងចម្ការដំណាំបន្ទាប់បន្សំផ្សេងៗ ទៅនឹងប្រាក់ចំណូលបានមកពីការដាំដំណាំស្វាយចន្ទីក្នុងមួយហិកតាដូចគ្នា។ តាមការវិភាគសេដ្ឋកិច្ចបង្ហាញឲ្យឃើញថា ប្រាក់ចំណូលបានមកពីដាំដំណាំស្វាយចន្ទីមានកំរិតខ្ពស់ជាងប្រាក់ចំណូលបានមកពីដំណាំស្រូវ និងដំណាំដំឡូង។ ចំណេះដឹងអំពីបច្ចេកទេសថ្មីផ្សេងៗ និងបទពិសោធន៍ល្អៗ គឺចាំបាច់ណាស់សម្រាប់យកមកអនុវត្តកែប្រែទំលាប់ចាស់ដែលគ្មានទំនោរទៅរកការវិវឌ្ឍន៍រីកចំរើន ដើម្បីរំដោះខ្លួនចេញពីភាពក្រីក្រដោយឈរលើការអភិវឌ្ឍន៍ខ្លួនឯង។

**លោក ស្រ៊ុ រាក់** ជាមេក្រុមនៃភូមិឧបសម្ព័ន្ធស្រែននបានសួរថា៖ តើប្រជាពលរដ្ឋអាចនឹងទទួលបានអ្វីខ្លះពីផែនការអភិវឌ្ឍន៍សហគមន៍នេះ?

**បណ្ឌិត លី សុពណ៌-មុនី** មានមតិឆ្លើយតបថា៖ អនុវត្តតាមកម្មវិធីលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈការជ្រើសរើសប្រភពចំណូលគ្រួសារ ដែលបានរៀបចំក្នុងផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍ ប្រជាពលរដ្ឋនឹងអាចទទួលបាននូវប្រាក់ចំណូលលើសពីប្រាក់ចំណូលដែលធ្លាប់ទទួលបានតាមទំលាប់កន្លងមក ពោលគឺ ការផ្លាស់ប្តូរពីការដាំស្រូវ ដាំដំឡូង ឬដំណាំបន្ទាប់បន្សំផ្សេងៗទៀត ដែលមានហានិភ័យខ្ពស់ក្នុងតំបន់ (គ្រោះទឹកជំនន់) ទៅជាការដាំដំណាំស្វាយចន្ទីដែលមានតម្លៃលើទីផ្សារខ្ពស់ ការចំណាយលើថ្លៃពលកម្មតិច (អនុវត្តការដាំដុះតែមួយដង ប៉ុន្តែទទួលផលរយៈពេលជាច្រើនឆ្នាំ) ហើយអាចប្រើប្រាស់សំណល់ផ្លែស្វាយចន្ទីសំរាប់ធ្វើជាចំណីសត្វជ្រូក ឬគោ និងមែកសំរាប់ធ្វើអុសដុតបានទៀតផង។

**លោក ស្រ៊ុ រាក់** មេក្រុមនៃភូមិឧបសម្ព័ន្ធស្រែននបានយល់ពីគោលបំណងនៃរៀបចំផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍នេះ រួចមានចេតនាចូលរួមក្នុងការអនុវត្តន៍កម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ ដោយចង់កែប្រែទំលាប់ដាំដុះដំណាំចម្ការរបស់គាត់នៅលើជើងភ្នំគ្រង់ ហើយគាត់នឹងផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃកម្មវិធីនេះដល់បណ្តាប្រជាពលរដ្ឋដទៃទៀតឲ្យមានការចាប់អារម្មណ៍ ហើយស្ម័គ្រចិត្តចូលរួមអនុវត្តផងដែរ។

ដោយសារមានវត្តមានតំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក នៅក្នុងការពិភាក្សាពិគ្រោះយោបល់នេះដែរនោះ **លោក ថេង ទ្រី** អនុក្រុមនៃភូមិឧបសម្ព័ន្ធស្រែននបានលើកឡើងថា៖ ប្រជាពលរដ្ឋក្នុងភូមិអាលចទាំងមូលកំពុងរង់ចាំមើលការអនុវត្តន៍នូវកិច្ចសន្យារបស់ក្រុមហ៊ុន ដែលបានធ្វើឡើងកាលពីនៅក្នុងជំនួបរវាងភាគីទាំងពីរ។

**លោក កែវ សុវណ្ណ** បុគ្គលិកក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក បានមានមតិឆ្លើយតបថា៖ ក្រុមហ៊ុនបាននិងកំពុងធ្វើសម្បទានយ៉ាងច្រើនដល់ប្រជាពលរដ្ឋ ហើយការយឺតយ៉ាវចំពោះការអនុវត្តន៍នូវកិច្ចសន្យារបស់ក្រុមហ៊ុនដែលមិនទាន់បានបំពេញ គឺដោយសារក្រុមហ៊ុនមានការមមាញឹកក្នុងការដាំដុះឲ្យ

បានទាន់ពេលវេលាក្នុងរដូវវស្សា។ ចំពោះការសន្យាទាំងឡាយ ក្រុមហ៊ុននឹងបំពេញនៅរដូវប្រាំងខាងមុខនេះ។

**លោកបណ្ឌិត លី សុពណ៌-មុនី** បានមានមតិបន្ថែមថា៖ យោងតាមការចុះសិក្សាសេដ្ឋកិច្ច-សង្គមរបស់ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស ចាប់ពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៤ ថ្មីៗនេះបានឲ្យដឹងថា ប្រជាពលរដ្ឋក្នុងភូមិឧបសម្ព័ន្ធស្រែនមានសំណូមពរសំខាន់ចង់បានអណ្តូងទឹក សាលាឆាន់មួយកន្លែងក្នុងភូមិ និង ប៉ុស្តិ៍សុខភាព។ ចំពោះសំណើទាំងនេះអាចទទួលបានពីប្រភពផ្សេង ពោលគឺ ប្រជាពលរដ្ឋអាចធ្វើសំណើសុំអណ្តូងទឹកទៅមន្ទីរអភិវឌ្ឍន៍ជនបទតាមរយៈអាជ្ញាធរឃុំ និងស្រុក។ ដោយឡែក ប៉ុស្តិ៍សុខភាពត្រូវធ្វើសំណើទៅមន្ទីរសុខាភិបាលខេត្ត។ ចំណែកឯសាលាឆាន់វិញ លោកនឹងស្វែងរកប្រភពដែលនឹងអាចទទួលបាន ព្រោះការសាងសង់សាលាឆាន់មិនមាននៅក្នុងផែនការមូលនិធិអភិវឌ្ឍន៍សហគមន៍នេះទេ។

កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់នេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំមួយ និងសាមសិបនាទីល្ងាច នៃថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងយោគយល់គ្នាទៅវិញទៅមក។

## ៦.២.៣ ការស្ទង់មតិជាមួយប្រជាជនមូលដ្ឋាន

- ប្រជាពលរដ្ឋមូលដ្ឋានទាំងអស់សម្តែងនូវការអបអរសាទរ ចំពោះវត្តមានរបស់ក្រុមហ៊ុនវិនិយោគដែលចូលមកធ្វើការវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូនៅក្នុងតំបន់ ព្រោះពួកគាត់ទទួលបាននូវអាទិភាពការងារ ដែលជាប្រភពចំណូលចម្បង អាចឲ្យគ្រួសារពួកគាត់មានជីវភាពល្អប្រសើរជាងមុន។ ជាក់ស្តែង ជីវភាពរបស់ពួកគាត់ គឺមានការរីកចំរើនជាងមុន ដោយសារពួកគាត់មានលទ្ធភាពប្រើប្រាស់ម៉ូតូ ៤នវិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃ និងអាគុយបំភ្លឺនៅពេលយប់ទៀតផង។
- ប្រជាពលរដ្ឋមូលដ្ឋានភាគច្រើនដែលរស់នៅតំបន់ដាច់ស្រយាល ធ្លាប់មានការពិបាកក្នុងការធ្វើដំណើរកាត់តាមផ្លូវព្រៃ កាត់ទឹកកាត់ភក់ និងចំណាយពេលវេលាយូរពីមុនមក អាចប្រើប្រាស់ផ្លូវមេបែងចែកអនុតំបន់នានារបស់ក្រុមហ៊ុន ក្នុងការធ្វើដំណើរទៅកាន់ទីប្រជុំជន មណ្ឌលសុខភាពក្នុងការទទួលនូវការព្យាបាលជួយសង្គ្រោះសមាជិកគ្រួសារ ពិសេសគឺកូនចៅពួកគាត់ដែលជាសិស្សានុសិស្សអាចធ្វើដំណើរទៅកាន់អនុវិទ្យាល័យ ឬវិទ្យាល័យនៅឯឃុំ បានយ៉ាងងាយស្រួល និងឆាប់រហ័ស ដើម្បីចាប់យកនូវចំណេះដឹងដែលជាទុនចិញ្ចឹមជីវិតទៅថ្ងៃអនាគត។ ដោយមានប្រព័ន្ធផ្លូវគមនាគមន៍ល្អប្រសើរ ធ្វើឲ្យជីវភាពរបស់ពួកគាត់ ក៏មានការរីកចំរើនជាងមុន ពីព្រោះពួកគាត់មានលទ្ធភាពដឹកជញ្ជូនកសិផលមកកាន់ទីផ្សារ និងមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅបានយ៉ាងទូលំទូលាយ ហើយទទួលបាននូវការយកចិត្តទុកដាក់ពីអង្គការនានា ក្នុងការទទួលបាននូវអណ្តូងទឹកស្អាត ការផ្សព្វផ្សាយនូវចំណេះដឹងផ្នែកអនាម័យ សុខភាព សុខមាលភាព និងវិធានការប្រយុទ្ធប្រឆាំងនឹងជម្ងឺឆ្លងមួយចំនួន (ជាក់ស្តែង ធ្វើឲ្យអត្រានៃអ្នកកើតជម្ងឺគ្រុនចាញ់ចុះទាប) ជាដើម។

## ៦.២.៤ ការស្ទង់មតិជាមួយប្រជាមូលដ្ឋានដែលរងនូវការប៉ះពាល់

- ប្រជាពលរដ្ឋមូលដ្ឋានដែលរងនូវការប៉ះពាល់ទាំងអស់ មានមុខរបរចិញ្ចឹមជីវិត ដោយពឹងផ្អែកលើ

Draft

ការធ្វើស្រែចំការ ចិញ្ចឹមសត្វ និងការរុករកផលអនុផលព្រៃឈើ។ ដោយសារតែមានការវិនិយោគលើដីសម្បទានសេដ្ឋកិច្ច ព្រៃដែលប្រជាពលរដ្ឋធ្លាប់ទទួលបានផលអនុផលព្រៃឈើពីមុន បានក្លាយជាចំការកៅស៊ូ ដូចនេះពួកគាត់បានងាកមករកការងារកសិកម្មជាចំបងវិញ។ ដោយឡែកការងារស៊ីឈ្នួលកាប់ឫស្សី កាប់ឈើ និងដឹកឈើ នៅតែជាការងារសំខាន់សម្រាប់ប្រជាពលរដ្ឋដែលគ្មាន ឬ មានដីស្រែចំការតិចតួចក្នុងការទទួលបាននូវប្រាក់ចំណូល ទោះបីជាធនធានដែលពួកគាត់កំពុងរុករកស្ថិតនៅកាន់តែឆ្ងាយទៅៗក៏ដោយ។ រីឯការនេសាទវិញ គឺគ្រាន់តែរកសម្រាប់ទុកហូបក្នុងគ្រួសារប៉ុណ្ណោះ។ ដោយសារការកាត់បង់ប្រាក់ចំណូលមួយផ្នែកដែលបានមកពីការអាស្រ័យធនធានធម្មជាតិនេះហើយ ពួកគាត់ចង់ឲ្យក្រុមហ៊ុនផ្តល់នូវអាទិភាពការងារដល់សមាជិកគ្រួសារពួកគាត់ឲ្យបានច្រើននាក់ផងដែរ ដើម្បីបានប្រាក់ខែយកមកទ្រទ្រង់ជីវភាពគ្រួសារ ជាជាងទៅរុករកធនធានធម្មជាតិនៅក្នុងតំបន់ឆ្ងាយនិងមានគ្រោះថ្នាក់ផងនោះ។

- ដោយសារមុខរបរចិញ្ចឹមសត្វគោ ក្របីជាប្រភពចំណូលសំខាន់សម្រាប់បង្កើននូវកម្រិតជីវភាពគ្រួសារ ហើយអាចលក់ដើម្បីដោះស្រាយនូវរាល់ពេលមានបញ្ហាទ័លច្រក និងនៅពេលមានធុរៈបុណ្យទាន របស់ពួកគាត់ផងនោះ ធ្វើឲ្យពួកគាត់មានការព្រួយបារម្ភណ៍លើការបាត់បង់នូវវាលស្មៅសម្រាប់លែងគោ ក្របីឲ្យវាស៊ី ពីគម្រោងវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូរបស់ក្រុមហ៊ុន។ អាស្រ័យហេតុនេះ បានជាមានការស្នើសូមឲ្យក្រុមហ៊ុនកាត់ចៀលនូវផ្ទៃដីទុកសម្រាប់ធ្វើជាវាលស្មៅដល់ពួកគាត់។
- ប្រជាជនមូលដ្ឋានដែលរងនូវការប៉ះពាល់ភាគច្រើនជាជនជាតិភាគតិច ធ្លាប់តែរស់នៅពឹងផ្អែកលើកត្តាធម្មជាតិទាំងស្រុង ដូច្នេះពួកគាត់ចាប់អារម្មណ៍តែទៅលើអ្វីដែលមានស្រាប់ក្នុងមជ្ឈដ្ឋានធម្មជាតិ។ ម្យ៉ាងទៀត ដោយពួកគាត់ខ្លះមានដីស្រែចម្ការតិចតួច និងខ្លះទៀតពុំមានដីស្រែឬចម្ការទាល់តែសោះ ហេតុនេះពួកគាត់មិនចាប់អារម្មណ៍នឹងសារៈប្រយោជន៍ នៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍សំរាប់អនុវត្តកម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើស នៃការរកប្រាក់ចំណូលគ្រួសារ ដូចជាការផ្លាស់ប្តូរការធ្វើស្រែតាមរដូវ ទៅជាដំណាំស្ទាយចន្ទីដែលផ្តល់ផលរយៈពេលវែងនោះទេ។ ចំពោះមុខ ពួកគាត់ចង់បានតែផ្លូវលំ អណ្តូងទឹកស្អាត សាលារៀន និងប៉ុស្តិ៍សុខភាពប៉ុណ្ណោះ។

## ៦.៣ ការសន្និដ្ឋានរួមលើលទ្ធផលនៃការពិគ្រោះយោបល់

- ក្រុមហ៊ុនបានអនុវត្តនូវបទបញ្ជាលេខ ០១ របស់រដ្ឋាភិបាល ដែលមានក្រុមនិស្សិតស្ម័គ្រចិត្តចុះមកវាស់វែងដោះស្រាយដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋរួចទាំងស្រុង។ ក្នុងនោះ ក្នុងអនុតំបន់ទី១ ក្រុមនិស្សិតបានចុះវាស់វែងកាត់នូវផ្ទៃដីចំនួន ១៨៥.៤១ហិកតា ក្នុងអនុតំបនទី២ បានកាត់ដីអស់ចំនួន ២៦៣,៩២ហិកតា ក្នុងអនុតំបន់ទី៣ បានកាត់ចេញនូវផ្ទៃដី ១១៨.៣៦ហិកតា និងក្នុងអនុតំបន់ទី៤ បានកាត់ចេញនូវផ្ទៃដី ១៣១.៤២ហិកតា ហើយដីទាំងអស់នេះត្រូវបានរៀបចំធ្វើប្លង់និងប្រគល់ប័ណ្ណកម្មសិទ្ធិកាន់កាប់រួចអស់ហើយ។

Draft

- ក្រោយពីមានការអន្តរាគមន៍ និងសម្របសម្រួលចំនួន ១១ដង ពីអាជ្ញាធរខេត្ត ក្រុមហ៊ុន ដូទីសាយហួន-ប៊ិញហ្វឿក (អេស ប៊ី ខេ) បានសុខចិត្តកាត់ជូនអ្នកភូមិប្បៀរនូវផ្ទៃដីចំនួន ៥៤៥,២៤ហិកតាទៀត ដូចនេះ ក្រុមហ៊ុនបានដោះស្រាយនូវបញ្ហាដីធ្លីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋបានចប់សព្វគ្រប់ទាំងស្រុងហើយ។

- ក្រៅពីក្រុមហ៊ុន ដូទីសាយហួន-ប៊ិញហ្វឿកបានកាត់ដីចំនួន ៥៥៦,៧៤ហិកតា ឲ្យប្រជាពលរដ្ឋភូមិប្បៀរចំនួន ២២៩គ្រួសារ ក្រុមហ៊ុនភូរៀងបានកាត់ដីចំនួន ១.០១៥ហិកតា និងក្រុមហ៊ុនម៉ូហ៊ីបាក់បានកាត់ដីចំនួន ៥២០ហិកតាផងដែរ។ ក្រៅពីនេះ ប្រជាពលរដ្ឋភូមិប្បៀរមានដីព្រៃសហគមន៍ចំនួន ៤៧០ហិកតាទៀត ដូច្នេះសរុបទៅ ពួកគាត់មានដីព្រៃ ២.៥៦១,៧៤ហិកតា សម្រាប់ប្រើប្រាស់ទៅថ្ងៃអនាគត។

- បន្ទាប់ពីក្រុមហ៊ុនដូទីសាយហួន-ប៊ិញហ្វឿក (អេស ប៊ី ខេ) បានដោះស្រាយកាត់ដីជូនប្រជាពលរដ្ឋពាក់ព័ន្ធរួចជាស្ថាពរហើយនោះ ទាំងអាជ្ញាធរខេត្ត ស្រុក ឃុំ ភូមិ និង ប្រជាពលរដ្ឋ មូលដ្ឋានទាំងអស់ (១០០%) សម្តែងនូវការអបអរសាទរ ចំពោះវត្តមានរបស់ក្រុមហ៊ុនវិនិយោគ ដែលចូលមកធ្វើការវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូនៅក្នុងតំបន់ ព្រោះពួកគាត់ទទួលបាននូវអាទិភាពការងារដែលជាប្រភពចំណូលចម្បង អាចឲ្យគ្រួសារពួកគាត់មានជីវភាពល្អប្រសើរជាងមុន និងកាត់បន្ថយបាននូវការធ្វើចំណាកស្រុករបស់សមាជិកគ្រួសាររបស់ពួកគាត់ ទៅស្វែងរក ការងារនៅទីឆ្ងាយៗ ដើម្បីបានប្រាក់ចំណូលជួយគ្រួសារផងដែរ។ លើសពីនេះទៅទៀតតាមរយៈ ការអភិវឌ្ឍន៍សង្គមរបស់ក្រុមហ៊ុន សព្វថ្ងៃក្រុមហ៊ុនបានសាងសង់ផ្លូវបែងចែងអនុតំបន់ និងផ្លូវមេព័ទ្ធព្រំដីក្រុមហ៊ុនដែលមានប្រវែងប្រមាណជា៨៩គ.ម ដែលបង្កលក្ខណៈឲ្យប្រជាពលរដ្ឋទាំងអស់អាច ប្រើប្រាស់ផ្លូវទាំងនោះ ដោយជិះម៉ូតូធ្វើដំណើរបានយ៉ាងស្រួល រួមទាំងអ្នកភូមិឧបសម្ព័ន្ធស្រែនន និងយ៉ែផងដែរ ដែលកាលពីមុនគាត់អាចធ្វើដំណើរនៅក្នុងតំបន់នោះបានតែតាមរយៈគោយន្ត និង រទេះគោប៉ុណ្ណោះ ឃើញថាពួកគាត់អាចមានទំនាក់ទំនងជាមួយតំបន់ខាងក្រៅបានទូលំទូលាយជាងមុនច្រើន ក៏ដូចជាការធ្វើដំណើរទៅកាន់ទីប្រជុំជន សាលារៀន និងមណ្ឌលសុខភាពជាដើម។

- ចំពោះព្រៃទ្រនាប់ដងអូរ ក្រុមហ៊ុនបានរក្សាទុកតាមការកំណត់របស់រាជរដ្ឋាភិបាល។ រីឯកម្លាំងពលកម្មដែលកំពុងបំរើការងារនៅក្នុងក្រុមហ៊ុនមានបុគ្គលិកសរុបជាង ៨០នាក់ ចំណែកចំនួនពលករគឺទាក់ទងទៅនឹងរដូវកាលនៃការដាំដុះដែលអាចមានរហូតដល់ជាង ៦០០នាក់។ ពលករម្នាក់រាចទទួលប្រាក់កម្រៃ ២០.០០០រៀលក្នុងមួយថ្ងៃ ដែលជាតម្លៃខ្ពស់ជាងគេនៅក្នុងតំបន់។

- ប្រជាពលរដ្ឋដែលបានចូលរួមក្នុងការពិគ្រោះយោបល់មិនសូវយកចិត្តទុកដាក់ និងចាប់អារម្មណ៍ចំពោះផែនការនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍សំរាប់អនុវត្តកម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសារទេ នេះអាចមក ពីពួកគាត់ភាគច្រើនជាជនជាតិភាគតិច ធ្លាប់តែរស់នៅពឹងផ្អែកលើកត្តាធម្មជាតិទាំងស្រុង ហើយពួកគាត់ចាប់អារម្មណ៍តែទៅលើអ្វីដែលមានស្រាប់ក្នុងមជ្ឈដ្ឋានធម្មជាតិ។ ម្យ៉ាងទៀត ដោយសារពួកគាត់ខ្លះមានដីស្រែចម្ការតិចតួច និងខ្លះទៀតពុំមានដីស្រែ ឬចម្ការទាល់តែសោះ ហេតុនេះ

ពួកគាត់មិនចាប់អារម្មណ៍នឹងសារៈប្រយោជន៍ នៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍សំរាប់អនុវត្តកម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសារ ដូចជាការផ្លាស់ប្តូរការធ្វើស្រែតាមរដូវកាល ទៅជាដំណាំស្វាយចន្ទីដែលផ្តល់ផលរយៈពេលវែងនោះទេ។ ចំពោះមុខ ពួកគាត់ចង់បានតែផ្លូវលំ អណ្តូងទឹកស្អាត សាលារៀន និងប៉ុស្តិ៍សុខភាពប៉ុណ្ណោះ។

- ចំពោះផែនការនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍សំរាប់អនុវត្តកម្មវិធីលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការផ្តល់នូវជំរើសនៃការរកប្រាក់ចំណូលគ្រួសារ ប្រជាពលរដ្ឋត្រូវលើកជាសំណើ និងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ ដែលជាលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់គ្នានៅថ្នាក់មូលដ្ឋាន មកក្រុមហ៊ុនតាមរយៈអាជ្ញាធរឃុំ ស្រុក ទីចាត់ការផែនការវិនិយោគខេត្ត ដោយមានការឯកភាពពីគណៈនៃគណៈអភិបាលខេត្តក្រចេះ។ ក្រុមហ៊ុន ដូទីសាយហ្គួន-បិញហ្សឿក (អេស ប៊ី ខេ) មានភារៈកិច្ចផ្តល់នូវមូលនិធិអភិវឌ្ឍន៍សហគមន៍របស់ខ្លួនចំនួន ២៥.០០០ ដុល្លាអាមេរិក និងការងារបច្ចេកទេស។ ចំណែកការត្រួតពិនិត្យ តាមដាន និងវាយតម្លៃជាភារៈកិច្ចរបស់ក្រុមហ៊ុនទីប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក សឺវីស។
- ការប្រើប្រាស់មូលនិធិដែលមានទឹកប្រាក់ ៣០.០០០ដុល្លាអាមេរិក/ឆ្នាំ សម្រាប់កម្មវិធីស្តារគុណភាពបរិស្ថាន នឹងត្រូវឆ្លងតាមរយៈការប្រជុំពិភាក្សាគ្នារវាងអាជ្ញាធរខេត្ត មន្ទីរពាក់ព័ន្ធ ក្រុមហ៊ុន ដូទីសាយហ្គួន-បិញហ្សឿក (អេស ប៊ី ខេ) និងក្រុមហ៊ុនប្រឹក្សា អ៊ិនវ៉ាយរ៉ូថេក សឺវីស ដើម្បីជ្រើសរើសយកពេលវេលាសមស្រប និងសកម្មភាពស្តារបរិស្ថានណាមួយ (ដូចជាការសាងសង់ប៉ុស្តិ៍យាមល្បាត និងការដាំកូនឈើជាដើម) រួមទាំងការរៀបចំជាកម្មវិធីបន្តបន្ទាប់នៅពេលអនាគតទៀតផង។